Reçu le 16-3-51 B. Centrale

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ៧

Mars

ខែ មីនា ព.ស. ២៤៩៤

ឆ្នាំសិក្សា ១៩៥០-៥១

ATIONALE
CAMBODGE
K-2
50-1951
(7)

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្តីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្តី សម្រាប់ គ្រូបង្រៀន

### បញ្ជីរឿង

| បញ្ជីរឿង | ទំព័រ |
|---|---|
| ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា | ៣ |
| មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា | ១២ |
| កុមារដ្ឋាន - បរិវច្ឆណដ្ឋាន ភាសា | ២៥ |
| មជ្ឈិមដ្ឋានទី២ - ឧត្តមដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ - ធរណីមាណសាស្ត្រ | ៣៤ |
| មជ្ឈិមដ្ឋានទី ១ និងអាទិកដ្ឋាន - ធរណីមាណសាស្ត្រ | ៤៧ |
| បរិវច្ឆណដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៤៨ |
| កុមារដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៥៣ |
| មជ្ឈិមដ្ឋានទី ២ - ឧត្តមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការរោគ | ៦០ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. | ៧៤ |
| កុមារដ្ឋាន - បរិវច្ឆណដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ | ៧៨ |
| លោកនីតិ | ៩១ |
| មេសូត្រតែមាត់ | ៩៣ |

# ឧត្តមញ្ញាណ

## សម្តេច ជួន-ណាត

ជួន-ណាត កើតនៅភូមិកំរៀង ស្រុកគងពិសី ។ កាលនៅក្មេងមានវ័យល្មមនៅក្តី អាពុកម្តាយយកទៅឲ្យនៅវត្តពោល្យំ ។ លុះរៀនបានចេះអានចេះសរសេរគួរសមហើយ ក៏សូមផ្នួសបួសជាសាមណេរនៅវត្តនោះឯង ។ ឯព្រះឧបជ្ឈាយ៍នាម ម៉ម លោកមានឈ្មោះល្បីល្បាញខាងទេសនាមហាជាតក៍ ។ ដោយកសនាដាស់តឿនលោកសាមណេរណាត ពុំយូរប៉ុន្មាននៅវត្តស្រុកស្រែ ក៏សូមលាលោកគ្រូឧបជ្ឈាយ៍មករៀនសូត្រឯក្រុងភ្នំពេញ នៅវត្តឧណ្ណាលោម ជ្រកកោនក្នុងកុដិព្រះគ្រូសោ ។ លោកគ្រូ សោ ក៏ទទួលឲ្យនៅដោយស្មោះស្មូន ហើយបានជួយទំនុកបម្រុងឲ្យរៀនព្រះត្រៃបិដកក្នុងសំណាក់អាចារ្យក្នុងវត្ត ។ លោកនេន ណាត ក៏ប្រឹងរៀនសូត្រដោយចិត្តក្លាហានចេះចាំពុំមានទាស់ចិត្តអាចារ្យឡើយ លោកអាចារ្យទាំងឡាយសឹងតែមានសេចក្តីសរសើរ លុះអាយុបាន ២១ ឆ្នាំហើយ លោកនេន ណាត សូមឧបសម្បទបំពេញជាភិក្ខុឯវត្តពោល្យំ រួចមកគង់វត្តឧណ្ណាលោមវិញ ។ លោកភិក្ខុ ណាត សប្បាយតែនឹងរៀនសូត្រ មិនត្រឹមតែភាសាខ្មែរ លោកចេះអានបាន

គម្ពីរ បាលី បិដក ជាអក្សរខ្មែរ អក្សរភូមា អក្សរសៀម អក្សរសិង្ហល (លង្កា) អក្សរឡាតាំង អក្សរសំស្រ្កឹត អក្សរលាវ ៗ សេចក្តីសរសើរអំពីលោកអាចារ្យចាស់ ៗ ទាំងឡាយ ឮសាយជ្រួតជ្រាបរហូតដល់ព្រះមហាសមណៈស្តេចសង្ឃ លោកអ្នកធំនៃរាជការអាណាចក្រ លោកភិក្ខុ ណាត ឡើងជាទីរាប់អាននៃអ្នកទាំងពួង បានឋានន្តរៈសក្តិជម្បូងជាព្រះគ្រូសំសត្ថា ៗ រាជការបាននិមន្តឲ្យទៅរៀនបំពេញវិជ្ជាអក្សរសំស្រ្កឹតឯគុងកឹង ក្នុងសាលាអ្នកប្រាជ្ញបុងបុញ្ញាប្រទេស ៗ បានតាំងជាក្រុមសន្និបាតធ្វើវចនានុក្រមខ្មែរ បានតាំងជាអាចារ្យសាលាបាលី តមកទៀតបានតាំងជាចាងហ្វាងរង នៃសាលាបាលីជាន់ខ្ពស់ រួចឡើងជាចាងហ្វាងពេញទី ៗ ក្នុងគណៈសង្ឃ លោកសំសត្ថា ណាត បានឡើងជាទីសាសនៈសោភណ រួចជាសេនាបតិសង្ឃទីព្រះពុទ្ធឃោសាចារ្យរួចជាព្រះពោធិវង្ស ព្រមទាំងបានតាំងជាចៅអធិការធំបណ្តប់លើវត្តឧណ្ណាលោម ដែលជាវត្តធំនៅស្រុកខ្មែរសម្រាប់ស្តេចសង្ឃ ៗ ហើយនៅថ្ងៃ ទី ១៨ ខែ មេសា ១៩៥០ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ប្រោសព្រះរាជទាន សមណស័ក្តិឡើងជាទីសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ៗ សម្តេចព្រះមហាសុមេធាធិបតី

ជួន-ណាត បានធ្វើវចនានុក្រមខ្មែរ បានធ្វើវេយ្យាករណ៍បាលី នឹងសៀវភៅធម៌ផ្សេង ៗ ច្រើនទៀត ។ សម្ដេចបាននិមន្ដទៅនគរលានសាង ( ដំរី ១ លាន គឺ លាវ ) ដោយរាជការសហ់តណ្ឌូចិននិមន្ដសម្ដេចទៅដើម្បីឲ្យជំបូន្មានពីផ្លូវប្រតិបត្តិក្នុងពុទ្ធសាសនាដល់បព្វជិត នូវឧបាសក ឧបាសិកា នៅប្រទេសនោះ ។

ពាក្យពន្យល់ · –

មហាជាតក៍ = ជាតិធំ, ទីនេះសំដៅយកគម្ពីរ វេស្សន្ដរ ។ ឋានន្ដរ = លំដាប់ស័ក្ដិយស ។ បុព្វប្រទេស = ប្រទេសខាងកើត ។ វចនានុក្រម = ក្បួនមើលលំដាប់ពាក្យ (Dictionnaire) ។ បព្វជិត = លោកសង្ឃ , អ្នកបួស ។

## សេចក្ដីសច្ចាប្រណិធានក្នុងបុរាណសម័យ

យើងមិនបានសរសើរព្រះរាជកិត្តិយសព្រះមហាក្សត្រិយ៍ណាក្រៅពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូងរបស់យើង ។ យើងមិនទទឹងទាស់នឹងព្រះរាជបំណង ហើយយើងមិនបានចូលដៃនឹងពួកបច្ចាមិត្តរបស់ព្រះអង្គ យើងមិនបានប្រព្រឹត្តនូវអំពើដែលនាំឲ្យវិនាសដល់ព្រះអង្គ

យើងខំប្រព្រឹត្តទូវអំពើដែលជាផលនៃអភិវឌ្ឍន៍នឹងកតវេទី ចំពោះព្រះករុណា; បើមានសង្គ្រាម យើងខំព្យាយាមចូលតស៊ូដោយពលភាពរបស់ចិត្ត ព្រមទាំងមិនគិតដល់ជីវិតសោះឡើយ, ដោយអភិវឌ្ឍន៍ចំពោះព្រះករុណាជាម្ចាស់ជីវិតលើត្បូង យើងមិនរត់ចេញឲ្យឆ្ងាយពីសមរភូមិ, បើមិនមានបម្រាំងទេ, យើងស៊ូស្លាប់ដោយសារធ្វើឃាតកម្មខ្លួនឯងឬដោយមរណៈភាព ។ យើងសូមឲ្យបានរង្វាន់ឬកិត្តិយសចំពោះបុគ្គលដែលមានចិត្តត្រង់នឹងចៅហ្វាយនាយ; យើងនឹងធ្វើការថ្វាយព្រះមហាក្សត្រិយ៍ទាល់តែខ្លួនមរណភាព បើសិនណាជាត្រូវស្លាប់ក្នុងពេលដែលធ្វើការនោះ, យើងនឹងបំពេញករណីយកិច្ចចំពោះព្រះមហាក្សត្រិយ៍ឥតមានរួញរាសោះឡើយ; បើមានកិច្ចការអ្វីដែលព្រះករុណាចាត់យើងទៅឆ្ងាយដោយមានព្រឹត្តិការណ៍ដែលព្រះអង្គបានជ្រាបជាមុន, យើងត្រូវខំប្រឹងប្រែងរករឿងនោះដោយពិស្តារ ។ បើបណ្ដាយើងទាំងអស់គ្នា មានអ្នកណាមិនព្រមធ្វើតាមសច្ចាប្រណិធាននោះ យើងសូមឲ្យព្រះមហាក្សត្រិយ៍ដែលសោយរាជ្យសម្បត្តិទៅអនាគត ធ្វើព្រះរាជទណ្ឌកម្មដល់អ្នកនោះ បើមានអ្នកណាក្បត់ព្រះអង្គ មិនព្រមធ្វើតាមពាក្យសច្ចាប្រណិធាន សូមឲ្យអ្នកនោះ ទៅរងទុក្ខលំបាកវេទនានៅមហានគរទាំងសាមសិបពីរ ឲ្យ

បានយូរអង្វែងស្មើនឹងសេចក្តីស្ថិតនៅនៃព្រះអាទិត្យនឹងព្រះចន្ទ ; បើបានប្រតិបត្តិតាមពាក្យសច្ចប្រណិធាន សូមឲ្យព្រះមហាក្សត្រិយ៍មានព្រះរាជតម្រាស់ថា បូជនីយដ្ឋានគ្រប់ទីកន្លែងក្នុងប្រទេស ត្រូវចាត់ឲ្យវង្សត្រកូលយើង មើលថែទាំកិត្តិយសនៃបុគ្គលដែលចិត្តត្រង់ ចំពោះព្រះមហាក្សត្រិយ៍ យើងសូមឲ្យបានសម្រេចចាប់ដើមអំពីលោកនេះ រហូតដល់បរលោក ។

## ពាក្យពន្យល់ ·–

បច្ចាមិត្ត = ( សំស្ក្រឹត = ប្រត្យាមិត្រ ) = សត្រូវ

អភិវន្ទន៍ = ( ឬអភិវាទន៍ ) = កិរិយាថ្វាយបង្គំដោយគោរព

កតវេទី = ដែលគិតតែងតបស្នងដល់អ្នកមានគុណ

ពលភាព = គឺភាពនៃកំឡាំង

ទីសមរភូមិ = គឺទីដែលធ្វើចម្បាំង

ព្រឹត្តិការណ៍ = ហេតុឬដំណើរដែលកើតមានឡើង

ធ្វើព្រះរាជទណ្ឌកម្ម = គឺធ្វើទោសឬផ្ដន្ទាទោសតាមកំហុស

នៅមហានគរទាំងសាមសិបពីរ = គឺនៅទីឋាននរក

បូជនីយដ្ឋាន = ឋានដែលជាទីគួរបូជា, គួរគោរព

# មជ្ឈិមដ្ឋាន ទី ២

## ឧកញ៉ាជួង

ក្នុងជាន់បុរាណក្ដី ជាន់ឥឡូវក្ដី គេពុំសូវឃើញមានច្រើន អ្នកដែលចេះវិជ្ជាហោរាសាស្ត្រឡើយ ។ ក្នុងប្រទេសនីមួយៗក្នុងរាជ្យស្ដេចនីមួយៗ គេឃើញមានហោរាតែមួយ ពីរ ឬបួនបើច្រើនណាស់ ។

ហោរាជាមនុស្សប្រភេទអ្វី? គឺជាអ្នកប្រាជ្ញមួយ បណ្ដាអ្នកប្រាជ្ញទាំង-ឡាយ ។ អ្នកប្រាជ្ញនេះចេះវិជ្ជាម្យ៉ាង ហៅវិជ្ជាហោរាសាស្ត្រ គឺវិជ្ជាបំណែកខាងមេឃ ដឹងគិតគោចរនៃព្រះគ្រោះ នូវផ្កាយរាសី ផ្កាយនក្ខត្តឫក្ស ដែលជាប្រធាននៃកាលកំណត់ ។ ដោយហេតុនោះហើយបានជាប្រក្រតិទិនដែលជាការហោរាទ្រទ្រង់កុំឲ្យវិនាសទៅបាន សករាជ ឆ្នាំ រដូវ ខែ ថ្ងៃ ពេលម៉ោងជួបប្រទះឯង ។ បើសិនណាជាគ្មានហោរាទេ បណ្ដាមហាជនក្នុងប្រទេសនឹងធ្លាក់ក្នុងទីងងឹតសូន្យឈឹង គឺថាម្នាក់ៗពុំអាចនឹងដឹងថាខ្លួនអាយុប៉ុន្មានផង ទោះក្នុងការរបរផ្សេងៗ ក៏ធ្វើពុំបាន ព្រោះសន្មតពេលវេលាមិនកើត ។

នៅប្រទេសខ្មែរ យើងនេះ ក្នុងរាជ្យព្រះបាទនរោត្តម មានហោរា

ម្នាក់ឈ្មោះដួង ដែលជាហោរាសំរាប់ផែនដី ។

ហោរាដួងនោះជាទេពកញ្ញ ហោរាទាំងពួកបានយកចិត្តទុកដាក់ណាស់ក្នុងក្រសួងនៃខ្លួន ។ ពោះលោកមានអាយុជាង ៧០ ឆ្នាំហើយក្ដី លោកពុំលះបង់ការព្យាយាមឡើយ ។ គេឃើញលេខអង្គាឡើងស័កជាច្រើនរយឆ្នាំ តាំងពីអតីតនឹងអនាគត សរសេរទុកក្នុងក្រាំងដើម្បីឲ្យហោរាឯក្រោយងាយស្រួលធ្វើការ ។ មិនតែប៉ុណ្ណោះលោកបានរៀបចំក្បួនខ្នាត បាននិទ្ទិ វិនិច្ឆ័យទុកឲ្យអ្នកឯក្រោយ សេចក្ដីណាដែលមិនច្បាស់លាស់ ។ មានបារាំងសែសម្នាក់ឈ្មោះ អេមិលហ្វារូ ដែលមានដំរិះជ្រៅជ្រះខាងនក្ខត្ត ។ បារាំងសែសនោះ ស្ទួមរៀនហោរាសាស្ត្រអំពីទេពកញ្ញដួង ។ ការរៀនសូត្រក៏បានសម្រេច បានប្រែក្បួនខ្មែរជាភាសាបារាំង ហើយបានបញ្ចេញពចាគោតស្វែង ដល់នក្ខត្តសាស្ត្រខ្មែរពីបូរាណ ដែលមានកន្ទែងខ្លះជ្រៅហួសប្រមាណ តាមសេចក្ដីប្រែស្រាយនៃជនក្នុងសម័យឥឡូវ ។

ពាក្យពន្យល់ ·–

ហោរាសាស្ត្រ = ក្បួននិយាយពីដំណើរព្រះគ្រោះ គឺព្រះអាទិត្យ, ចន្ទ្រ, អង្គារ, ពុធ, ព្រហស្បតិ, សុក្រ, សៅរ៍, កេតុ, រា ។

រាសី = ហ្វូងផ្កាយដែលគេចែកមេឃ ជា១២ ល្វែងរៀបរៀងគ្នាជុំ

ផ្កាយមេរុ (étoile polaire) ។ ព្រះអាទិត្យចរផុតរាសីមួយ ៗ អស់កំឡុង ៣១ ថ្ងៃ ។ រាសីទាំង ១២ មានឈ្មោះគឺ ១ មេស, ២ ឧសភ, ៣ មិថុន, ៤ កក្កដ, ៥ សីហ៍, ៦ កញ្ញ, ៧ តុល, ៨ វិច្ឆិកា, ៩ ធ្នូ, ១០ មករ, ១១ កុម្ភ, ១២ មីន ។

នក្ខត្តឫក្ស = ហ្វូងផ្កាយដែលគេចែកមេឃជា ២៧ ល្វែងរៀបរៀងតាមរាសី ជាសំរាប់ដំណើរព្រះចន្ទ្រ ។ ល្វែងមួយ ៗ ហៅឫក្ស នោះព្រះចន្ទ្រចរគង់កំឡុង ១ ថ្ងៃផុតឫក្ស ១ ; ឈ្មោះខែយើងសង់ជាឈ្មោះឫក្សទាំងអស់ ។

---

## កិត្តិយសដល់បុគ្គលដែលស្លាប់បាត់ទៅ

សូមកិត្តិយសមានដល់បុគ្គលទាំងឡាយ ដែលបាត់បង់ជីវិតទៅហើយ ដល់បុគ្គលទាំងឡាយ ដែលដួលស្លាប់ចុះដោយមានសេចក្តីសង្ឃឹមជាប់នៅក្នុងចិត្ត នៅដោយគន្ធដែលប្រឡាក់សុទ្ធតែឈាហិត, ក្នុងវេលាណាស្ថានដែលបាក់បែកខ្ទេចខ្ទី ក្នុងសំពៅនៃមហាគង្គាហើយ ដែលមានក្តុកចិត្តជិតទៅហើយ ពុំបានឃើញរស្មីនៃកិត្តិគុណរះលេចឡើងនឹងពន្លឺ នៃសន្តិភាពចាំងមក ។

សូមឲ្យមានកិត្តិយសដល់អ្នកដែលមានភាពតូចតាច ដែលរស់នៅដោយស្ងាត់កំបាំង ហើយដែលគេពុំអាចនឹងស្គាល់បាន ៗ មិនដែលមានបុរសឯណាមួយទៀតដែលមរណភាព ពុំបានជួយស្រោចស្រង់ប្រ-ទេសជាតិឲ្យរស់រានមានជីវិតឡើងវិញ នឹងចំឡងលោកទាំងមូលឲ្យផុតអំពីកណ្ដាប់ដៃនៃបច្ចាមិត្តកំណាច ៗ

សព្វអ្នកទាំងនោះដែលដាច់ដោចដោយគ្រាប់បែក ដេកដួលរាយប៉ាយនៅនាទីសមរភូមិដែលត្រូវពួកបច្ចាមិត្រលុកលុយ ហើយដែលជាទីដែលសាសនាទាំងមូលនឹងសម្រេច ៗ តែទោះយ៉ាងដូចម្ដេចក្ដី ក៏រូបភាពយ៉ាងប្រសើរនៃអ្នកទាំងនោះ ឋិតនៅយ៉ាងខ្ជាប់ខ្ជួនក្នុងដួងចិត្តយើងរាល់គ្នាពុំអាចនឹងរលុបឡើយ ៗ

## ពាក្យពន្យល់

លេណដ្ឋាន = ទីដែលសម្រាប់ជ្រកនឹងគ្រាប់បែក ( la tranchée)

កិត្តិគុណ = គឺជ័យជំនះ ( la gloire )

សន្តិភាព = ភាពដែលគ្មានចំបាំង ភាពនៃសេចក្ដីសន្តិសុខ

មរណភាព = សេចក្ដីស្លាប់

សមរភូមិ = ទីចំបាំង (champ de bataille)

រូបភាព = គឺស្រមោលនៃរូប

# មេរៀនទី ១

## រៀនមើល – ពាក្យ – ភាសា

### រឿងខ្លាឃ្មុំនឹងដើមពង្រ

មានខ្លាឃ្មុំមួយទៅដេកនៅក្រោមដើមពង្រ ១ លុះដេកលក់បន្តិចទៅ មែកពង្របាក់ធ្លាក់មកត្រូវក្បាល ខ្លាឃ្មុំក៏ភ្ញាក់ក្រោកឡើងមម្ងមា បានក្ដីឈឺក្បាលពន់ពេកណាស់ ក៏ដើរចេញចាកទីនោះ ហើយទឹកខឹងនឹងដើមពង្រ ចងអាឃាតថា អាដើមពង្រនេះអញកំពុងដេកលក់សុខសប្បាយវាទម្លាក់មែកមកលើក្បាលអញ បានកើតទុក្ខវេទនាមានសភាពយ៉ាងនេះ បើអញបានឱកាសកាលណា អញនឹងរំលំរំលើងវាឲ្យអស់ពូជតែម្ដង ខ្លាឃ្មុំមានគំនុំចងពៀរនឹងដើមពង្រដូច្នេះហើយ ក៏ដើរត្រាច់តាមដងព្រៃ ទៅកាន់ទីតាមក្ដីប្រាថ្នា ។

កាលនោះមានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ជួនជាភ្លៅរទេះបាក់កំឈប់ ហើយកាន់ពូថៅដើរចូលព្រៃ ដើម្បីកាប់ឈើធ្វើភ្លៅរទេះ លុះដើរៗទៅបានជួបនឹងខ្លាឃ្មុំកណ្ដាលព្រៃ ខ្លាឃ្មុំក៏សួរថា អ្នកបងដើរ

រកអ្វី? ចៅនោះក៏ប្រាប់ថា យើងដើររកកាប់ឈើធ្វើក្ដាររទេះ ខ្លាឃ្មុំបានឮដូច្នោះបានឱកាសទើបប្រាប់ទៅថា ឈើសម្រាប់ធ្វើក្ដាររទេះគ្មានឈើអ្វីឲ្យក្រៀត ជាប់ដូចដើមពង្រទេ ចូរអ្នកឯងទៅកាប់ដើមពង្រឯណោះចុះ ចំពោះជាធ្វើក្ដាររទេះជាប់ល្អណាស់ ចាហើយក៏នាំផ្លូវ ចៅនោះទៅកាន់ដើមពង្រ ហើយដើរចេញពីទីនោះទៅហោង ។

ពន្យល់ពាក្យ = ខ្លាឃ្មុំ.- ចតុប្បាទសម្បុរខ្មៅ បរិភោគឃ្មុំជាអាហារ ។ ពង្រ = ឈ្មោះដើមឈើធំមួយយ៉ាង មានសាច់រឹង មានផ្លែប្រើជាម្ហូប ។ ចងអាឃាត = ចងចិត្តគុំបំរុងនឹងធ្វើព្យាបាទ ។ ចងពៀរ = គំពៀរឲ្យមានជាប់ទៅក្នុងជាតិខាងមុខ ។ ក្ដាររទេះ = ស្នូលមូលសកក្នុងដុំសម្រាប់ឲ្យដុំវិល ។

ហាត់ភាសា.- ខ្លាឃ្មុំជាអ្វី?- ខ្លាឃ្មុំដេកនៅឯណា? ហេតុអ្វីបានជាវាភ្ញាក់ក្រោកឡើង?- ខ្លាឃ្មុំចងគំនុំនឹងដើមពង្រដូចម្ដេចខ្លះ? ខ្លាឃ្មុំដើរទៅជួបនឹងអ្នកណា ? ខ្លាឃ្មុំសួរទៅអ្នករទេះថាដូចម្ដេច? អ្នករទេះនោះឆ្លើយប្រាប់ថាដូចម្ដេច ? ខ្លាឃ្មុំពន្យល់អ្នករទេះនោះដូចម្ដេចខ្លះ? ពន្យល់រួចហើយខ្លាឃ្មុំនោះវាធ្វើម្ដេចទៀត ? ។

# ភាសិកដ្ឋាន

## បង្រៀនពាក្យនិងភាសា

អាទិត្យទី ១ .– អំពីរុក្ខជាតិដែលមានសរសៃត្បាញបាន

នាម .- កប្បាស គរ ធ្មៃ ម្នាស់ បេក ត្រគៀតប៉ោង កៅស៊ូ ឫស្សី សំឡី ជ័រ សរសៃអន្ទង់ សរសៃចាក់ កី ផ្នះ បោះ កប្បាស សំលៀកបំពាក់ សំពត់អម្បោះ ។

គុណនាម .– ទន់ រឹង ស្វិត យឺត ជាប់ ផុយ មាំ ឆ្មារ ថ្មោស រលើង រលើប គគ្រាត ។

កិរិយាសព្ទ .– កាត់ខោ – អាវ ដេរសំលៀកបំពាក់ បោះកប្បាស ត្រាំក្រចៅ ធ្មៃ – រវៃអម្បោះ ផ្ដួចសំឡី ខារអម្បោះ អន្ទង់ ត្បាញ សកសំបក ។

ហាត់ភាសា.- សំលៀកបំពាក់ដែលយើងស្លៀកពាក់សព្វថ្ងៃបាន មកពីអ្វីខ្លះ? (បានមកអំពីរុក្ខជាតិនិងសត្វ) អ្នកស្គាល់រុក្ខជាតិអ្វីខ្លះ ដែល

មានសរសៃត្បាញបាន? នៅភូមិអ្នកមានគេដាំកប្បាសឬទេ? កប្បាសគេដាំច្រើននៅទីណា? នៅខែណា? ផ្លែកប្បាសទុំនៅខែណា? កាលណាផ្លែកប្បាសបែករីកគេធ្វើដូចម្ដេច? គេយកកប្បាសទៅធ្វើដូចម្ដេចទើបបានជាសំឡី? ខ្មែរយើងយកសំឡីកប្បាសទៅធ្វើអ្វី? (យកទៅធ្វើអម្បោះគួយ ត្បាញសំពត់កាត់ខោអាវធ្វើជាក្រមាជូតទឹក ធ្វើស្បៃមុង ។ល។)។

ការហាត់សរសេរ.— ១— ចូរឆ្លើយឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ៖ សំលៀកបំពាក់យើងប្រើប្រាស់សព្វថ្ងៃបានមកអំពីអ្វីខ្លះ? រុក្ខជាតិណាខ្លះដែលមានសរសៃត្បាញបាន? ។

២.— សុំឲ្យរើសយកពាក្យ នាម គុណនាម កិរិយាសព្ទខ្លះមកដាក់ឲ្យសិស្សតែងធ្វើជាឃ្លាផង ។

## បង្រៀនមើល

## សិប្បិយការកើតពីសត្វ

សៀវភៅវត្ថុស្ងាឆ្ងាយន៍អាទិកដ្ឋានទំព័រ ១៥០ ។

ហាត់ភាសា.– សំពត់សូត្រយ៉ាងល្អគេធ្វើនឹងអ្វី? ដើម្បីនឹងស្រាវយកសរសៃសូត្រអ្នកស្រុកអាយយកសំបុកសូត្រទៅធ្វើម្ដេចខ្លះ? ព្រោះអ្វីបានជាគេយកសំបុកសូត្រទៅស្រុសក្នុងទឹកពុះហើយកូរនឹងចង្កឹះ? គេស្រាវសូត្រ-នឹងអ្វី? ស្រាវរួចហើយគេធ្វើម្ដេចទៀត? ។ល។

## សរសេរតាមសូត្រ

### អំពីដើមកប្បាស

ដើមកប្បាសជារុក្ខជាតិតូច កំពស់មួយម៉ែត្រឬមួយម៉ែត្រកន្លះ គ្រាប់វាសម្បុរសឬលឿង មានសំឡីរុំព័ទ្ធជុំវិញ ផ្លែបែបជាឡូតមានគ្រាប់នឹងរោមទន់ល្មើយនៅក្នុង គឺរោមនោះហើយដែលហៅថាសំឡីកប្បាសដុះលើដីធូរហើយមានដីច្រើនផង ។

គេដាំកប្បាសនៅខែបុស្ស–មាឃ ហើយគេបេះយកផ្លែវា នៅខែជេស្ឋឬអាសាឍ ។ នៅស្រុកខ្មែរគេដាំកប្បាសនៅមាត់ទន្លេមេគុងក្នុងខេត្តកំពង់ចាមនឹងខេត្តកណ្ដាល ។

កប្បាសសម្រាប់ត្បាញធ្វើសំពត់ហៅថាសំពត់អំបោះ គេយកគ្រាប់

វាទៅស្ងួតប្រេងសំរាប់អុជ – ម៉ាស៊ីន ហើយនឹងធ្វើសាប៊ូ កាកសម្រាប់ធ្វើជី

សរសេរពាក្យពិបាក. កប្បាស – រុក្ខជាតិ – សម្បុរ – សរុំ – ព័ន្ធ – ដុះ – បុស្ស – មាឃ – ជេស្ឋ – អាសាឍ – កំពង់ – កណ្ដាល – ទន្លេ – ប្រេង – អុជ – លាង ។

## តែងសេចក្ដី

ចូរឆ្លើយតាមពាក្យចោទសួរដូចខាងក្រោមនេះ ៖

ពោតជាដំណាំគេដាំយកអ្វី ? – ដើមវាមានកំពស់ប៉ុន្មានម៉ែត្រ ? ស្លឹកវាយ៉ាងដូចម្ដេច ? – ផ្កាវាមានប៉ុន្មានយ៉ាង ? – នៅដើមនិមួយៗមានផ្កាប៉ុន្មាន? គ្រាប់ពោតមូលមានពណ៌ដូចម្ដេច ? ។ ពោតមានប្រយោជន៍ដូចម្ដេចខ្លះ?

## អក្សរផ្ចង់

ព ឮ ឭ ឈ ញ ឱ

ពតែញើ ស្រុកពញាឮ ឭងកាលណោះ

ឮគេថា ចៅពញារក្សាភិបាល ។

# បង្រៀនពាក្យ នឹង ភាសា

## អាទិត្យទី ២.- អំពីរោងកិនស្រូវ

នាម.- ស្រូវ ស្រូវខ្សាយ ស្រូវដំណើប អង្ករ អង្កាម ម្សៅ កន្ទក់ ត្បាល់ជាន់ (ត្បាល់កឿន) ត្បាល់កិន ត្បាល់បុក កញ្ច្រែង កញ្ឆើ ល្អី បាវ រោងម៉ាស៊ីន (រោងយន្ត) ។

គុណនាម.- ធ្ងន់ ស្រាល រហ័ស យឺត ខ្ទប ល្អិត ម៉ដ្ឋ ជ្រាយ ។

កិរិយាសព្ទ.- កិន ជាន់ បុក បក់អង្កាម រែងកន្ទក់ ហាលស្រូវ បោយស្រូវ ។

ហាត់ភាសា.- គេធ្វើដូចម្ដេចដើម្បីនឹងយកអង្កាមចេញ។ តួត្បាល់កិនខាងលើ (ខាងក្រោម) យ៉ាងដូចម្ដេច? គេធ្វើនឹងអ្វី? ដើម្បីនឹងកិនស្រូវ គេដាក់ដៃត្បាល់នៅឯណា? គេច្រកស្រូវនៅឯណា? តួត្បាល់ខាងក្រោមភ្ជាប់នៅនឹងអ្វី? លុះកិនស្រូវរួចហើយគេធ្វើដូចម្ដេចទៀត? ត្បាល់ជាន់បែបយ៉ាងដូចម្ដេច? អ្នកដែលជាន់អង្ករឬទេ? គេជាន់ប៉ុន្មានអន្លើទើបអង្ករស? ។ល។

ការហាត់សរសេរ ៖— ចូលតែងជាឃ្លានឹងពាក្យខាងក្រោមនេះ៖

ស្រូវ- អង្ករ- អង្កាម- កន្ទក់- ម្សៅ ។

ឧទាហរណ៍ ។ — ពីម្សិលមិញខ្ញុំជួយកិនស្រូវបងប្រុសខ្ញុំអស់ចំនួនប្រាំថាំង ។ គេយកអង្ករសំរូបទៅជាន់បុកឲ្យសធ្វើជាអង្ករសំរិត ។

## បង្រៀនមើល

### រោងកិនស្រូវ

សៀវភៅដដែលទំព័រ ១៣២ តាំងពី មុននឹងយកស្រូវមកប្រើការ រហូតដល់..... ឯនៅស្រុកហាណូយនិងហៃហ្វុង នឹងភ្នំពេញគេឃើញមានរោងកិនស្រូវដែរ ។

ពន្យល់ពាក្យ ៖— កិន = កិ. សង្កត់ឲ្យបែក : កិនស្រូវ កិនគ្រួស ។ ជាន់ = កិ. ដាក់ជើងសង្កត់ស៊ប់ពីលើ ។ ជាន់អង្ករ បុកអង្ករនឹងត្បាល់ជាន់ ។ កញ្ច្រែង = ន. ប្រដាប់ប្រើត្បាញនឹងបន្ទោះដូច ល្អី, កញ្ជើ តែត្បាញរង្វើល ៗ កញ្ច្រែងរាងជ្រៅប្រហោង.

ធំសំរាប់ដាក់ត្រី, កញ្ច្រែងរាងរាក់ហើយរាបរហោងតូចៗ សំរាប់រែងអង្ករ ៗ ត្បាល់ = ន. ប្រដាប់សំរាប់ប្រើខាងបុក, កិន, ដាន់ បកស្រូវជាដើម, ត្បាល់មានច្រើនយ៉ាង: ត្បាល់កិន មានមេ, គ្របតោ, ធ្មេញ, ដែលសំរាប់កិនស្រូវជាដើម ។ល។ ត្បាល់ដាន់ ឬត្បាល់ក្តឿង ត្បាល់ដែលមានអង្រែជាប់នឹងដងសំរាប់ដាន់ បុកស្រូវជាដើម ។

## ហាត់ភាសានិងហាត់សរសេរ.— ( សូមធ្វើដូចមុន )

## សរសេរតាមសូត្រ

### អំពីហាលស្រូវ

កាលពីថ្ងៃអាទិត្យមុន មេឃស្រឡះ ព្រះអាទិត្យបញ្ចេញចំហាយខ្លាំងណាស់ ម្តាយខ្ញុំបាទប្រើបងខ្ញុំហើយនឹងខ្ញុំឲ្យហាលស្រូវ ព្រោះជិតអស់អង្ករបរិភោគហើយ នោះបងខ្ញុំហើយនឹងខ្ញុំបាទក៏យកកន្ទេលស្លឹកត្នោតមួយធំទៅក្រាលលើដីមួយកន្លែងរាបស្មើក្នុងទីធ្លា រួចយកកញ្ជើមួយម្នាក់កើបស្រូវពីជង្រុកប្រហែលជាបីថាំង យកទៅចាក់ដាក់លើកន្ទេលនោះ ហើយរាបស្រូវឲ្យមានកំរាស់ស្មើគ្នា តាំងអស់ពេញកន្ទេល

ខ្ញុំបាទនៅចាំមើល កុំឲ្យមាន់ទាមកស៊ី មកហួរស្រូវ ហើយខ្ញុំបាទរើស្រូវម្ដង ៗផង ដើម្បីឲ្យស្ងួតសព្វទាំងអស់ ។

សរសេរពាក្យពិបាក.– អាទិត្យ - មេឃ - បរិភោគ - បញ្ចេញ - រាបស្មើ - កញ្ជើ - ជង្រុក - វាប - សព្វ ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីការធ្វើអង្ករ តាំងពីហាលស្រូវ កិនស្រូវ ដរាបដល់បានជាអង្ករស (អង្ករសម្រិត) តើខ្មែរយើងធ្វើយ៉ាងម្ដេចខ្លះ? ការនេះជាការនឿយហត់ច្រើនឬទេ? អ្នកយល់ឃើញដូចម្ដេច? ។

### ទំនងតែង

១– សេចក្ដីផ្ដើម.– (នៅវេលាណាដែលគេហាលស្រូវ គេធ្វើដូចម្ដេចខ្លះ)? ។

២– សេចក្ដីរៀបរាប់.– គេកិនស្រូវនឹងអ្វី? – គេកិនយ៉ាងដូចម្ដេច? – គេជាន់អង្ករនឹងអ្វី? – គេអុំ-រែងឬបក់អង្ករនឹងអ្វី? – ព្រោះអ្វីបានជាគេអុំ? ។

៣- យោបល់របស់អ្នក .- អ្នកយល់ឃើញដូចម្តេច? - ការនេះនឿយហត់ច្រើនឬទេ? - គេធ្វើដូចម្តេចវិញឲ្យបានឆាប់ជាង? ។

## អក្សរផ្ចង់

ង ជ ដ ផ ឯ ងងុយដេក ដេង

ដោង ដួងជក់ដកដង្ហើម ដើរផុង ឯកឯង

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ៣.- អំពីថ្នាំ

នាម.- គ្រាប់ថ្នាំ ផ្លែថ្នាំ ស្លឹកថ្នាំ កូនថ្នាំ ថ្នាល រមូរស្លឹកថ្នាំ សរសៃថ្នាំ ជ្រញ់ កាំបិត ថែប ខ្សៀ បារី ។

គុណនាម.- ថ្នាំខ្លាំង ខ្សោយ មូល ស្តើង ក្រាស់ ឆ្ងារ ថ្ពុស ស្ងួត សើម គ្រប់គ្រាន់ ក្រហមព្រឿង ស្វាយ ។

កិរិយាសព្ទ.- ព្រោះគ្រាប់ថ្នាំ ដាំកូនថ្នាំ បេះស្លឹកថ្នាំ ជន្លំថ្នាំ ហាន់ថ្នាំ ហាលថ្នាំ យកសន្សើមថ្នាំ មូរបារីញាត់ខ្សៀ ជក់បារី បុកថ្នាំ ។

ហាត់និយាយ.– ថ្នាំជាដំណាំគេដាំយកអ្វី? ដើម្បីនឹងដាំថ្នាំគេធ្វើដូចម្ដេច? ពេលណាដែលគេដកកូនថ្នាំពីថ្នាលយកទៅដាំក្នុងចំការ? គេដាំចម្ងាយពីគ្នាប្រហែលប៉ុន្មានសង់ទីម៉ែត្រ? ដាំរួចហើយគេធ្វើដូចម្ដេចទៀត? កាលណាបេះស្លឹកថ្នាំ គេបេះស្លឹកថ្នាំយកទៅធ្វើដូចម្ដេចខ្លះ នឹងមូរជាបារីបាន ? គេហាន់ថ្នាំនឹងអ្វី ?(សុំឲ្យគ្រូរកប្រដាប់បង្ហាញសិស្ស)ហាន់រួចហើយគេធ្វើដូចម្ដេចទៀត ? ។

## បង្រៀនមើល

សៀវភៅដែលទំព័រ ១៣៩ តាំងពី គេបេះស្លឹកថ្នាំហើយគេយកមករុំជារមូរបន្ទុំទុកក្នុងម្លប់ . . . រហូតដល់ គេដាំថ្នាំមិនបានចំនួនគ្រប់គ្រាន់អាស្រ័យទេ ។

ពន្យល់ពាក្យ.– ថែប= ន. ផែនធ្វើពីឫស្សី, បបុស ឬស្លឹកត្នោត ស្លឹកចាកជាដើម សំរាប់ហាលថ្នាំ ។ ថែប =កិ. ប៉ះដែកល្អនឹងដែកអន់ ដើម្បីឲ្យមុត ។ ថែប = ន. ដែកអាសេរ្យ ឬដែកអាសៀក ដែកថែប ។

## សរសេរតាមសូត្រ

### អំពីការធ្វើថ្នាំ

យកតាមសេចក្ដីដែលបានបង្រៀនមើលខាងលើនេះ តាំងពី គេដាំថ្នាំគ្រប់កន្លែងក្នុងប្រទេសឥណ្ឌូចិន - . . . រហូតដល់ . . . . ហើយយកទៅហាលថ្ងៃបានពីរឬបីថ្ងៃ ។

សរសេរពាក្យពិបាក.– រុំ - បន្ទុំ - រមូរ - ហាន់ - ជ្រញ់ - រុញ - ឫស្សី - ថែប - ខ្សៀ ។

## តែងសេចក្ដី

ចូរអធិប្បាយអំពីការធ្វើថ្នាំ ដែលអ្នកបានឃើញឬបានឮគេនិយាយថាតើការនោះគេធ្វើដូចម្ដេចខ្លះ តាំងពីដាំថ្នាំឡើង រហូតដល់បេះស្លឹកហាន់បានជាសរសៃរួចហាលបត់បានជាឡើឬទាញ់ថ្នាំស្រេច? - អ្នកយល់ឃើញថាគួរដាំថ្នាំឲ្យបានច្រើនឬទេនៅស្រុកយើង ? ។

## ទំនងតែង

១.– សេចក្ដីផ្ដើម.– (នៅភូមិអ្នកមានគេដាំថ្នាំឬទេ ?. វេលាណាដែលគេព្រោះគ្រាប់ថ្នាំ គេធ្វើដូចម្ដេច ?)

២.– សេចក្ដីរៀបរាប់.– គេដកកូនថ្នាំទៅដាំនៅក្នុងចំការ (គេធ្វើដូចម្ដេចខ្លះ ?) ការថែទាំកូនថ្នាំ (គេធ្វើដូចម្ដេចខ្លះ? ) គេបេះស្លឹកថ្នាំយ៉ាងណា ហើយគេយកស្លឹកនោះទៅធ្វើដូចម្ដេច ? ការហាន់និងហាលថ្នាំ (គេធ្វើដូចម្ដេច? ) គេយកសរសៃថ្នាំមកធ្វើដូចម្ដេចខ្លះ? ។

៣.– សេចក្ដីបញ្ចប់.– អ្នកយល់ឃើញដូចម្ដេចអំពីការធ្វើថ្នាំ? ។

### អក្សរផ្ចង់

ង ជ ដ ផ ឯ កុំជីកឃាក

កុំដេកទាល់ថ្ងៃ កុំជក់បារីក្នុងមុង

# កុមារដ្ឋាន

## បង្រៀនពាក្យនឹងភាសា

### អាទិត្យទី ១ .- អំពីក្រុមញាតិ

នាម .- វង្សត្រកូល , ពូជ , ញាតិ , ( ជំណាមនុស្សត ៗ ដោយឈាមជាមួយ ) សាខា ( មែក ) សាខាញាតិ , ញាតិពិសន្តាន ( ញាតិពីជួរ ) ញាតិពន្ធ ( ញាតិមិនតគ្នាដោយឈាមជាមួយ ) ញាតិជិត , ញាតិឆ្ងាយ , ញាតិក្នុងស្រុក ៗ

គុណនាម .- ខ្ពស់ , ទាប , ថោក , ថ្លៃ , មាន , ក្ររហោមរហាម , គោកយ៉ក , ដាច់ដាប , ខិលខូច , ៗ

កិរិយា .- ទំនុកបំរុង , ការពារ , គោរព , បង់កេរ្តិ៍ , រក្សាកេរ្តិ៍ , ជៀលត្នុះ ៗ

ហាត់ភាសា .- គេហៅថាអ្វី ជំណាមនុស្សដែលកើតត ៗមក? មនុស្សយ៉ាងដូចម្តេចដែលសំដីត្នុះហៅមនុស្សឥតត្រកូល ? ( មនុស្សខិលខូច ) ៗ ដែលហៅមនុស្សមានត្រកូល ? ( មនុស្សមានបុក

ខ្ពស់ ) ។ ញាតិទាំងឡាយមានប៉ុន្មានជំពូក ? ( ពីរជំពូក គឺ ញាតិជិតនឹងញាតិឆ្ងាយ ឬ សាខាញាតិ ) ។ ញាតិពន្ធនោះគឺជាញាតិយ៉ាងដូចម្តេច ? ( គឺជាញាតិខាងប្តីនឹងខាងប្រពន្ធ ) ។

## អាទិត្យទី ២ .— អំពីក្រុមញាតិ ( ត )

នាម .— ឪពុក ( បិតា ) ម្តាយ ( មាតា ) កូនប្រុស កូនស្រី បង, ប្អូន, អាយុ ។

គុណនាម .— ធំ, តូច, ក្មេង, ចាស់, លីវ, ជំទង់, ច្រើន

កិរិយា .— បង្កើត, ចិញ្ចឹម, ថែទាំ, ស្រឡាញ់, កោតខ្លាច ។

ភាសា .— ក្នុងក្រុមញាតិអ្នកមានអ្នកណាខ្លះ ? ឪពុកម្តាយអ្នកមានកូនប៉ុន្មាន ? អ្នកណាខ្លះ ? បងប្រុសអ្នកអាយុប៉ុន្មាន ? គាត់មានប្រពន្ធហើយ ឬ នៅលីវ ? កូនប្រុសស្រីត្រូវធ្វើម្តេចនឹងឪពុកម្តាយ ? បងប្អូនប្រុសស្រីត្រូវធ្វើម្តេចនឹងគ្នា ។

## អាទិត្យទី ៣.— អំពីក្រុមញាតិ ( ត )

នាម .— ជីតា, ជីដូន, ឪពុកធំ, ម្តាយធំ, មា, មីង, បងប្អូនជីដូនមួយ, បងប្អូនជីទួតមួយ, ចៅ, ក្មួយ, ក្មួយជីដូនមួយ ។

គុណនាម .– ចាស់, ជរា, អនិច្ចកម្ម, រស់, ស្លាប់, ញ័រ (ដៃ) កោង (ខ្នង) ។

កិរិយា .– ឈ្លោះប្រកែក, គោរពប្រតិបត្តិ, ទំនុកបំរុង, ស្លាប់បង្គាប់, ទូន្មាន, និយាយរឿង ។

ភាសា .– ជីតាអ្នកអាយុប៉ុន្មាន ? ជីដូនអ្នកនៅរស់ ឬអនិច្ចកម្មហើយ ? គាត់ដើរទៅណា ឆ្ងាយបានឬទេ ? ពីព្រោះអ្វី ? ជើងដៃគាត់ដូចម្ដេច ? អ្នកមានឪពុកម្ដាយធំឬទេ ? គាត់នៅឯណា ? គាត់រកស៊ីធ្វើអ្វី ? គាត់មានកូនប្រុសស្រីប៉ុន្មាន ? មាអ្នកត្រូវជាម្ដេចនឹងឪពុកអ្នក ? ដូចម្ដេចដែលហៅថាបងប្អូនជីដូនមួយ ? បងប្អូនជីដូនមួយអ្នកត្រូវជាម្ដេចនឹងឪពុកម្ដាយអ្នក ? ហេតុអ្វីបានជាត្រូវគោរពប្រតិបត្តិជីដូនជីតា ? ដើម្បីឲ្យឪពុកម្ដាយសប្បាយចិត្តអ្នកត្រូវធ្វើដូចម្ដេច ? ។

## អាទិត្យទី ៤ .– អំពីក្រុមញាតិ (ត)

នាម .– ឪពុកក្មេក, ម្ដាយក្មេក, បងថ្លៃ, ប្អូនថ្លៃ, កូនប្រសា ក្មួយប្រសា ។

គុណនាម .– កាច, ស្លូត, ល្អ, អាក្រក់, សុខសប្បាយ, ឈឺ ។

កិរិយា.– និយាយគួរសំ, – និយាយលេង, រាប់អាន, ជួយគ្នា, ដោះទុក្ខគ្នា, ប្រកាន់ទោស, ធ្វើងកង្រើង ។

ភាសា.– (សុំតែងពាក្យចោទសួរសិស្សតាមរៀងផង)

## រៀនមើលសរសេរ

### អាទិត្យទី ១.– ក្រុមញាតិបៅកេត

សៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ៩៥, ៩៦)

### អាទិត្យទី ២.– បងប្អូនបៅកេត

(វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៧)

### អាទិត្យទី ៣.– ស្រឡាញ់បងប្អូន

(វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៩)

### អាទិត្យទី ៤.– ត្រូវស្រឡាញ់គោរពខ្លាចជីដូនជីតា

ជីដូនជីតាយើងគាត់នឿយព្រួយលំបាកនឹងចិញ្ចឹមឪពុកម្ដាយយើង ដូចជាមាតាបិតាយើងនឿយហត់នឹងរកចិញ្ចឹមយើងដែរ ហើយមួយទៀតជីដូន

ជីតាយើងគាត់ថែទាំរក្សាយើងទៀតផង វេលាដែលឪពុកម្ដាយយើងមិននៅទៅធ្វើការ ; ហេតុនេះយើងត្រូវស្រឡាញ់ជីដូនជីតាយើងដូចជាយើងស្នេហាមាតាបិតាយើងដែរ ។

# បរិច្ឆណាថ្នាក់

## បង្រៀនពាក្យនឹងភាសា

### អាទិត្យទី ១.– នេសាទត្រី

នាម.– នេសាទ, ព្រាន (អ្នកធ្វើរបរនឹងចាប់សត្វព្រៃឬសត្វទឹកយកមកចិញ្ចឹមជីវិត ហៅថានេសាទឬព្រាន), ព្រានសន្ទូច, ព្រានសំណាញ់, ព្រានឈ្នស់, ព្រានសំពស់, ព្រានមង, អួន, អញ្ចូង ។

គុណនាម.– អ្នកនេសាទស្ទាក់, ឆ្នៃ, ការនេសាទបរិបូណ៌, ប្រ-សើរ, មាំមួន, រប៉ិចរប៉ី ។

កិរិយា.– នេសាទត្រី, ដឹកអួន, បង់សំណាញ់, ពាក់មង, អូសអញ្ចូង, គៀរត្រី, ពាយអួន, ហាលត្រី, ប្រឡាក់ត្រី ។

ភាសា.— កន្លែងនេសាទធំៗ មាននៅឯណា? (ទន្លេ, បឹង, ទន្លេសាប, ឈូងសមុទ្រកំពត) មនុស្សជាតិអ្វីដែលធ្វើរបរជានេសាទធំ ៗ? (យួន, ចាម) ។

## ពាក្យដែលត្រូវបង្រៀនតទៅទៀតក្នុងអាទិត្យជម្រុង

នាម.— នេសាទុបករណ៍ (គ្រឿងប្រដាប់សំរាប់នេសាទ) ថ្នង ឈ្នក់ , លប , ដង , ទ្រូ , ប្យូក , ស្នូ , សន្ទូច , ព្រួល , លាន់ , ឈ្នាង អង្រុត , គន , សំណាញ់ ។

គុណនាម.— ឆ្នស់មាំ , សម្រាស់ញឹក , ប្យកស្រួច , អួនវែង ។

កិរិយា.— លាមង , ភយ៉អួន , លើកដង , ដងត្រី , ទ្រាប , ដាក់ទ្រូ , ពួយប្យក , សត្រី , ទស់សម្រាស់ , គ្រាំឈ្នាង , ដឹកគន់ , ក្រុងត្រី , រុត , អញ្ញាត់ , បាច ។

### រៀនមើល

១ – អំពីនេសាទត្រី

(សៀវភៅខេមរ.បរិ.ទំព័រ ៨៧)

ពន្យល់ពាក្យ.– នុយ = ដុំសាច់ ឬប្រហុកដែលគេបិទនៅក្នុង សន្ទូច ។

កំសួល = ដុំឈើឬស្នោចង៏ក្ជាប់នឹងខ្សែសន្ទូចដើម្បីឲ្យសន្ទូចអណ្តែត ។

ពាក្យខុស= ត្រីរស់ ឲ្យសរសេរត្រីរស់ ។ អាស្រែ ឲ្យសរសេរ អាស្រ័យ ។

## ២.– អំពីពេលអាស្រ័យបាយឆ្ងាញ់

(សៀវភៅដដែលទំព័រ ៤៥)

ពាក្យសរសេរខុស – អាស្រែ សម្ងរ ស្មគ្គ ដោយសា

ត្រូវសរសេរ – អាស្រ័យ សម្ល ស្ម័គ្រ ដោយសារ

### សរសេរតាមសូត្រ

សុំឲ្យយករឿងមើលមកធ្វើដូចប្រក្រតី ប៉ុន្តែសុំកុំភ្លេចនឹងបន្ទឹកសិស្សឲ្យសរសេរពាក្យពិបាកជាមុននៅក្ដារខ្មៀន ដូចពាក្យ : នេសាទ សន្ទូច ដើរ កន្ត្រាញ់ បោះ លិច វាត់ អាស្រ័យ ។

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ២ .– ផលនៃនេសាទ

នាម .– ត្រី, បង្កង, អណ្ដើក, កន្ធាយ បបែល, អន្ទង់ លៀស, គ្រំ, ខ្យង ។ ត្រីប្រា, ត្រីព្រួល, ត្រីគល់រាំង ត្រីត្រសក់, ត្រីព្រលូង, ត្រីរស់, ត្រីឆ្ដោ, ត្រីបង្វា, ត្រីកែស, ត្រីក្រពាត់, ត្រីឆ្វាំង, ត្រីពោ, ឆ្លាម ។

គុណនាម .– ត្រីប្រលូងពុល, ឆ្លាមកាច, ត្រីគល់រាំងធំ ស្បែកបបែលគគ្រាត, ខ្លាញ់ខាប់, ត្រីឆ្អើរក្រៀម, បង្កងស្រស់ ត្រីងៀតស្ងួត ។

កិរិយា .– ធ្វើត្រី, វះពោះ, ស្រកា, ប្រៀកងៀត ប្រឡាក់អំបិល, ហាល, ឆ្អើរ, រំអាស់, បំហៀរ, លក់បញ្ចាន, ជូន ។

## រៀនមើល

១ – ការប្រយោជន៍ដល់អ្នកទាំងពួង

(សៀវភៅខេមរភាសាទំព័រ ១០)

ពាក្យសរសេរខុសក្នុងសៀវភៅត្រូវកែជា: កំពោរ, សូត្រ, មិន, ដោយសារ, នាយក, ត្រួតត្រា, ពាក្យចោទ

## សរសេរតាមសូត្រ

(សុំឲ្យធ្វើដូចប្រក្រតី គឺយករឿងមើលមកធ្វើ)

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី៣និងទី៤.– អាហារកើតឡើងអំពីផលនៃនេសាទ

នាម.– ងៀត, ឆ្អើរ, ប្រហុក, ផ្អក, កាពិ, ទឹកត្រី, បង្គា, ម្ហូប ៗ

គុណនាម.– ងៀតក្រៀម, ត្រីឆ្អើរស្វិត, ស្រួយ, ប្រហុកខ្ទោះ, ឈ្ងុយ, ផ្អកជូរ, ខុល, កាពិប្រៃ, ទឹកត្រីឈ្ងុយ, ថ្លា, គ្រឿង ៗ

កិរិយា.– ឆ្អើរត្រី, ធ្វើប្រហុក, ចាក់ផ្អក, រំងាស់ទឹកត្រី, ប្រោះ, ស្ល, ចៀន, ចំអិន, បរិភោគ ៗ

# រៀនមើល

## បិណ្ឌប្បាតិកសូត្រ – ត្រី

(វត្ថុស្វាធ្យាយន៍ទំព័រ ៣៨)

ពាក្យខុសក្នុងសៀវភៅត្រូវកែ = ស្រមុទជាសមុទ្រ ឬសមុទ្ទ ។

---

## មជ្ឈិមដ្ឋាន ទី ២ និង ឧត្តមដ្ឋាន

# នព្វន្ត

## អាទិត្យទី ១.– អំពីលេខភាគ (ត)

១.– លេខគុណចំនួនបែងភាគនឹងចំនួនបែងភាគ ។

ឧទាហរណ៍ : $\frac{៥}{៧}$ គុណនឹង $\frac{៣}{៤}$ ត្រូវធ្វើដូចខាងក្រោមនេះ ៖

$$\frac{៥}{៧} \times \frac{៣}{៤} = \frac{៥ \times ៣}{៧ \times ៤} = \frac{១៥}{២៨} \text{ ។}$$

វិធាន.– នឹងគុណលេខចំនួនបែងភាគនឹងបែងភាគដូចគ្នា ត្រូវគុណភាគយកនឹងភាគយក ភាគបែងនឹងភាគបែង ។

២.— លេខគុណចំនួនបែងភាគនឹងចំនួនគត់នឹងភាគ ។

ឧទាហរណ៍ : ៣៥ $\frac{២}{៣}$ គុណនឹង ៥ $\frac{៣}{៤}$ លេខតាំងទាំងពីរនេះជាចំនួនគត់នឹងភាគ មុននឹងធ្វើលេខ ត្រូវរំលាយចំនួនទាំងពីរនេះឲ្យទៅជាភាគយកលើសភាគបែង រួចទើបគុណបាន ។

$$៣៥\frac{២}{៣} = \frac{(៣៥ \times ៣) + ២}{៣} = \frac{១០៧}{៣}$$

$$៥\frac{៣}{៤} = \frac{(៥ \times ៤) + ៣}{៤} = \frac{២៣}{៤}$$

$$\frac{១០៧}{៣} \times \frac{២៣}{៤} = \frac{១០៧ \times ២៣}{៣ \times ៤} = \frac{២៤៦១}{១២}$$

**ឬ** $៣៥\frac{២}{៣} \times ៥\frac{៣}{៤} = \frac{(៣៥ \times ៣) + ២}{៣} \times \frac{(៥ \times ៤) + ៣}{៤} =$

$$\frac{១០៧}{៣} \times \frac{២៣}{៤} = \frac{១០៧ \times ២៣}{៣ \times ៤} = \frac{២៤៦១}{១២}$$ ។

វិធាន.— បើគុណលេខចំនួនគត់និងភាគនឹងចំនួនគត់និងភាគនោះ ត្រូវរំលាយចំនួនទាំងនោះឲ្យទៅជាចំនួនភាគយកលើសភាគបែងរួចទើបគុណដូចជាគុណចំនួនបែងភាគនឹងចំនួនបែងភាគ ។ សូមមើលរបៀបទី ១ ខាងលើនេះ ។

ការហាត់ .– ចូរធ្វើលេខខាងក្រោមនេះ ៖

$\frac{១}{២} \times \frac{៣}{៤} =$ $\frac{៤}{៥} \times \frac{៥}{៨} =$ $៤\frac{១}{៣} \times ២\frac{៥}{២៦} =$

$\frac{៥}{៦} \times \frac{១}{៣} =$ $\frac{៧}{៨} \times \frac{១៣}{២៥} =$ $៣\frac{១}{៨} \times ៣\frac{២}{៨} =$

បំណោទ.– ឈ្មួញម្នាក់បានលក់ស្រូវ ១៦៨ កាំងតូ ថ្លៃ ៦៥៛,៥០ មួយកាំងតាល់ តើឈ្មួញនោះបានចំណេញប៉ុន្មានបើគេដឹងថាថ្លៃដើមមានចំនួន $\frac{៤}{៥}$ កង់ថ្លៃលក់ ? ។

ទូមួយថ្លៃលើសតុ ១០ រៀល ឯតុថ្លៃ $\frac{៣}{៤}$ នៃថ្លៃទូ តើវត្ថុនិមួយៗ ថ្លៃប៉ុន្មានរៀល ? ។

អាទិត្យទី ២ .– លេខគុណចំនួនបែងភាគនឹងចំនួនគត់ ។

ឧទាហរណ៍: $\frac{៥}{៧} \times ៤ = \frac{៥ \times ៤}{៧} = \frac{២០}{៧}$

វិធាន.– ដើម្បីនឹងគុណចំនួនបែងភាគនឹងចំនួនគត់ ត្រូវគុណភាគយកនឹងចំនួនគត់ ហើយទុកភាគបែងនៅដដែល ។

២.– លេខគុណចំនួនគត់នឹងចំនួនបែងភាគ ។

ឧទាហរណ៍: $១៧ \times \frac{៥}{៦} = \frac{១៧ \times ៥}{៦} = \frac{៨៥}{៦}$ ។

វិធាន.– ដើម្បីគុណចំនួនគត់នឹងចំនួនបែងភាគ ត្រូវគុណចំនួនគត់នឹងភាគយក ហើយគេទុកភាគបែងឲ្យនៅដដែល ។

ការហាត់ .– ចូរធ្វើលេខខាងក្រោមនេះ៖

$\frac{៧}{១៥} \times ៥ =$ $\frac{៣}{៨} \times ៩ =$ $\frac{៧}{២០} \times ១០ =$

$១៤ \times \frac{៥}{៦} =$ $៨ \times \frac{២}{៣} =$ $៧ \times \frac{៥}{៦} =$

បំណោទ .– មនុស្សម្នាក់ទិញកំណាត់ ៨ ម៉ែត្រថ្លៃ ៩៦៛០០ រួចទិញ ៨ ម. $\frac{៣}{៨}$ ទៀត តើមនុស្សនោះចំណាយប្រាក់ទិញកំណាត់ទាំងអស់ប៉ុន្មានរៀល ? ។

អាទិត្យទី ៣ .– លេខចែកចំនួនបែងភាគ ។

១ – ចែកចំនួនបែងភាគនឹងចំនួនគត់ ។

ឧទាហរណ៍: $\frac{២}{៣} : ៥ = \frac{២}{៣ \times ៥} = \frac{២}{១៥}$ ។

វិធាន: ដើម្បីចែកចំនួនបែងភាគនឹងចំនួនគត់ ត្រូវគុណភាគបែងនឹងចំនួន ទុកភាគយកឲ្យនៅដូចដើម ។

២ .– បើកាលណាភាគយកចែកនឹងចំនួនគត់ដាច់ គេត្រូវចែកភាគយកនឹងចំនួនគត់ ដូចខាងក្រោមនេះ៖ ។

$$\frac{៦}{៧} : ៣ = \frac{៦:៣}{៧} = \frac{២}{៧}$$

៣ .– ចែកចំនួនគត់នឹងចំនួនបែងភាគ ។

ឧទាហរណ៍ : $៩ : \frac{២}{៣} = \frac{៩ \times ៣}{២} = \frac{២៧}{២}$

វិធាន .— ដើម្បីចែកចំនួនគត់នឹងចំនួនបែងភាគ ត្រូវគុណចំនួនគត់នឹងចំនួនបែងភាគ ដោយផ្លាស់ប្ដូរក្រោមជាលើ ៗ ជាក្រោមវិញ ។

អាទិត្យទី ៤.— ១– លេខចែកចំនួនបែងភាគនឹងចំនួនបែងភាគ ។

ឧទាហរណ៍: $\frac{៧}{៩} : \frac{២}{១៥} = \frac{៧ \times ១៥}{៩ \times ២} = \frac{១០៥}{១៨}$ ។

វិធាន.— ដើម្បីចែកចំនួនបែងភាគនឹងចំនួនបែងភាគ គេគុណចំនួនបែងភាគតាំងនឹងចំនួនបែងភាគជើងហារ ដោយផ្លាស់ប្ដូរភាគលើជាក្រោម ៗ ជាលើវិញ ។

២.— លេខចែកចំនួនបែងភាគនឹងចំនួនទសភាគ ឬ ចំនួនទសភាគចែកនឹងចំនួនបែងភាគ ។

ឧទាហរណ៍: $\frac{២}{៣} : ០,៤ = \frac{២ \times ១}{៣ \times ០,៤}$ ; $០,៤ : \frac{២}{៣} = \frac{០,៤ \times ៣}{២}$

$$\frac{៣}{៤} : ២,៥ = \frac{៣}{៤ \times ២,៥}$$

វិធាន.— នឹងចែកចំនួនទសភាគនឹងចំនួនបែងភាគ ឬ ចំនួនបែងភាគនឹងចំនួនទសភាគ គេត្រូវធ្វើលេខដូចជាចែកនឹងចំនួនគត់ដែរ ។ សូមមើលអាទិត្យទី ៣ ។

៣ — លេខចែកចំនួនគត់នឹងភាគ នឹងចំនួនគត់នឹងភាគ ។

ឧទាហរណ៍: $៦\frac{២}{៥} : ៤\frac{៣}{៤} =$ នេះត្រូវរំលាយចំនួនទាំងពីរ នេះឲ្យទៅជាចំនួនភាគយកលើសភាគបែង ។

$៦\frac{២}{៥}$ រំលាយទៅជា $\frac{៣២}{៥}$ $៤\frac{៣}{៤} = \frac{១៩}{៤}$ $\frac{៣២}{៥} : \frac{១៩}{៤} = \frac{៣២ \times ៤}{៥ \times ១៩}$

របៀបរំលាយនេះបានរៀនពីភាគទី ១ រួចហើយ

វិធាន:— ដើម្បីចែកចំនួនគត់នឹងភាគនឹងចំនួនគត់នឹងភាគនោះត្រូវរំលាយចំនួនគត់នឹងភាគឲ្យទៅជាចំនួនបែងភាគមានភាគយកលើសភាគបែងរួចទើបចែកដូចចែកលេខបែងភាគធម្មតា ។

ការហាត់ — ចូរធ្វើលេខខាងក្រោមនេះ ៖

$១៥ : \frac{១០}{៣} =$ $\frac{៣២}{១៥} : ៨ =$ $៩\frac{៤}{៥} :$ $៧\frac{៦}{១៥} =$

$៤២ : \frac{៧}{៤} =$ $\frac{៦៣}{១១} : ៩ =$ $៨\frac{៣}{៤} :$ $៧\frac{១}{៥} =$

បំណោទ — ចំពួយម៉ាស៊ីនទឹកមួយបញ្ចេញទឹកក្នុង ៤ ម៉ោងពេញអាងមួយ ចំពួយមួយទៀតបញ្ចេញ ៦ ម៉ោងទើបពេញអាងដដែលនេះ ។ បើចំពួយទាំងពីរនេះបញ្ចេញទឹកព្រមគ្នាក្នុងរវាង ២ ម៉ោង $\frac{១}{៤}$ តើបានទឹកប៉ុន្មានភាគក្នុងអាងនោះ ។

# រង្វាស់រង្វាល់

## អំពីរង្វាល់ដែលមានរូប ។

រង្វាល់ដែលតូចជាងលីត្រនោះគឺ:

| | | |
|---|---|---|
| សង់ទីលីត្រ (ស.ល) | តូចជាងលីត្រ | ១០០ ដង |
| ទ្វេសង់ទីលីត្រ | ” | ៥០ ដង |
| កន្លះដេស៊ីលីត្រ | ” | ២០ ដង |
| ដេស៊ីលីត្រ (ដ.ល.) | ” | ១០ ដង |
| ទ្វេដេស៊ីលីត្រ | ” | ៥ ដង |
| កន្លះលីត្រ | ” | ២ ដង |

រង្វាល់ដែលធំជាងលីត្រ គឺ: លីត្រ (ល)

| | | | |
|---|---|---|---|
| ទ្វេលីត្រ | ធំជាងលីត្រ | ២ | ដង |
| កន្លះដេកាលីត្រ | ” | ៥ | ” |
| ដេកាលីត្រ (ដា.ល) | ” | ១០ | ” |
| ទ្វេដេកាលីត្រ | ” | ២០ | ” |
| កន្លះហិកតូលីត្រ | ” | ៥០ | ” |
| ហិកតូលីត្រ (ហ.ល) | ” | ១០០ | ” |

រង្វាល់ទាំងអស់នេះមានរាងជាបំពង់ទាំងអស់ ហើយធ្វើពីឈើ (សម្រាប់វាល់វត្ថុក្រៀម) ពីសំណប៉ាហាំង ឬពីដែកសវិឡាត (សម្រាប់វាល់វត្ថុរាវ ទឹកដោះ ប្រេង ។ល។) ធ្វើពីដែកឬស្ពាន់ (សម្រាប់វាល់វត្ថុរាវលក់ដុំ) ។

រង្វាល់ដែលធ្វើពីសំណប៉ាហាំងរាងជាបំពង់ ហើយមានជំរៅទ្វេពីបន្ទាត់ពុះនៃបាត ឯរង្វាល់ឯទៀតមានកំពស់ស្មើនឹងបន្ទាត់ពុះនៃបាតទាំងអស់ ។

ការហាត់ .— ធុងមួយកំពស់ ៤០ស.ម ទទឹងប្រវែង១៥ស.ម បណ្ដោយ ២០ស.ម តើធុងនោះបំណុះទឹកប៉ុន្មានលីត្រ ? ។ សូមរកការហាត់បែបនេះដាក់ឲ្យសិស្សរកឲ្យបានច្រើន ។

ចំណោទ .— ជង្រុកមួយទទឹង ៤ ម៉ែត្រ បណ្ដោយ៥ម៉ែត្រ ដាក់ស្រូវដល់កំពស់ ១ម៉ែ៥០ តើស្រូវនៅក្នុងជង្រុកនោះទម្ងន់ប៉ុន្មាន? បើគេដឹងថាស្រូវ១ហិកតូលីត្រទម្ងន់ ៥៥ គីឡូក្រាម ។

# ធរណីមាណសាស្ត្រ

## អំពីរាងបំពង់

អណ្ដូង សសរលេញ ( សសរផ្ទះ ) លីត្រ បម្រើងបន្ទប់ ទៀនដៃ ។ល។ គឺជាវត្ថុមានរាងហៅថា " រាងបំពង់ " ។



បណ្ដោយរង្វង់មណ្ឌល

វិធីបង្រៀន សូមគ្រូយកក្រដាសមួយសន្លឹកមូរហើយភ្ជាប់មុខគ្នា រួចប្រាប់សិស្សថា នេះជារាងបំពង់ បើលបំពង់នេះទៅវិញបានជារាងជ្រុងបួនទ្រវែង ដូច្នេះទីរកផ្ទៃក្រៅនៃរាងបំពង់ត្រូវយកកំពស់គុណនឹងបរិវេណរង្វង់មណ្ឌល ( ពីរមេគុណ )

ផ្ទៃក្រៅ = កម្ពស់ × $2\pi R$ ឬ $2\pi RH$

ទីរកផ្ទៃសរុបត្រូវថែមផ្ទៃបាតទាំងពីរទៅលើផ្ទៃក្រៅទៀត ។

ផ្ទៃសរុប = $2\pi RH + 2\pi R^2$ .

ទីធរកចំនួនទំហំកងបំពង់ត្រូវយកផ្ទៃបាតគុណនឹងកំពស់ ។

$$ចំនួនទំហំ = \pi R^{២} \times កំពស់ ឬ \pi R^{២} h$$

## អំពីហាមមណ្ឌល (la couronne)



ហាមមណ្ឌល

ដែលហៅថាហាមមណ្ឌល គឺជាផ្ទៃនៅក្នុងរណ្ឌមណ្ឌលពីរ ដែលមានស្តូលតែមួយ ដូចយ៉ាងខ្ទង់កង់រទេះ ។

ស្ថ. ១- ជាកាំតូច (រ៉ី)

ស្ថ. ន- ជាកាំធំ (រ៉េង)

ទីធរកផ្ទៃហាមមណ្ឌលតូចទៅកាត់ផ្ទៃមណ្ឌលធំ ។

ឧទាហរណ៍: មណ្ឌលមួយ (ផ្ទៃមូល) មានកាំតូច ៣ ម៉ែត្រ កាំធំ៥.ម តើផ្ទៃហាមមណ្ឌល នោះប៉ុន្មានម៉ែត្រក្រឡា ? ។

ទីធរកផ្ទៃហាមមណ្ឌលនោះត្រូវធ្វើដូច្នេះ ៖

ផ្ទៃមណ្ឌលធំ $= \pi R^{២} = ៣,១៤ \times ៥ \times ៥ = ៧៨,៥០$ $ម^{២}$

តូច $= \pi R^{២} = ៣,១៤ \times ៣ \times ៣ = ២៨,២៦$ $ម^{២}$

ផ្ទៃហាមមណ្ឌល = ៧៨,$^{ម២}$៥០ − ២៨,២៦ = ៥០$^{ម}$,$^{២}$២៤

អំពីហាមមណ្ឌលជាបំពង់ (le manchon cylindrique)

បំពង់ទឹក បំពង់សូត្រ មាត់អណ្តូងធ្វើពីឥដ្ឋ សុទ្ធតែជាវត្ថុមានរាង ជាហាមមណ្ឌលបំពង់ ៗ




ក ខ គ ឃ នេះជាករណ៍ហាមមណ្ឌលបំពង់ ៗ នឹងរកចំនួនទំហំផ្ទៃហាមមណ្ឌលបំពង់ ត្រូវយកផ្ទៃក្រោមមណ្ឌល គុណនឹងកំពស់ ៗ

**បំណោទ** .– កង់រទេះមួយកំពស់ ១,$^{ម}$៧៥ ៗ តើចំនួនទំហំផ្ទៃឈើធ្វើកង់នេះប៉ុន្មាន ? បើគេដឹងថាកាំហើយនឹងដុំរទេះ ធ្វើអស់ឈើ ៣៥០ ដ.ម.$^{៣}$ ហើយឯកម្រាស់ហើយនឹងសម្រង់ខ្លួនកង់នោះ ១០ស.ម. ៗ

បំពង់សំណមួយបណ្ដោយ ១ម៉ែត្រ បន្ទាត់ផ្ចិតខាងក្នុងប្រវែង ២ សម. ៤ កម្រាស់ ៦ម.ម តើបំពង់នោះទម្ងន់ប៉ុន្មាន ? ៗ (សំណ១ ដ.ម ៣ ទម្ងន់ ១១ គ្រ, ៣៥)

អណ្តូងមួយមូលរៀបអិដ្ឋធ្វើជាជញ្ជាំងជុំវិញកម្រាស់ ០ម,៣០ ជំរៅ ៦,ម ៥០ ឯកាំខាងក្នុងវាស់មាត់អណ្តូង ០,ម ៩០ តើថ្លៃជញ្ជាំងនោះប៉ុន្មាន ? បើគេដឹងថាក្នុងជញ្ជាំង ១ម៣ ថ្លៃ ៨៥ រៀល ។

---

## មជ្ឈមដ្ឋានទី ១ និងអាទិកដ្ឋាន

## ធរណីមាណសាស្ត្រ

### អាទិត្យទី១និងទី២.— បាត - កំពស់ - ផ្ទៃនៃត្រីកោណ:

សេចក្តីរំឭក.— ត្រីកោណមានជ្រុងបី ក្នុងជ្រុងទាំងបីគេអាចយកជ្រុងណាមួយធ្វើជាបាតបានតាមចិត្ត ឯកំពស់ក៏ដូចគ្នាដែរ គេបង្គូសកំពស់ចេញពីកំពូលណាក៏បាន ក៏ប៉ុន្តែគង់សារគិតគូរផ្ទៃគេត្រូវយកកំពស់ណាដែលធ្លាក់មកលើបាតដែលគេបានវាស់ហើយនោះ ។

ការរកផ្ទៃនៃត្រីកោណ .—

ប្រដាប់បង្រៀន – ក្រដាសកាតបួនជ្រុងទ្រវែងនិងបួនជ្រុងព្នាយស្រប ។




តាមគំនូរនេះ ក្រឡាផ្ទៃនៃត្រីកោណស្មើនឹងពាក់កណ្ដាលផ្ទៃនៃបួនជ្រុងទ្រវែង ឬបួនជ្រុងព្នាយស្រប ដែលមានទំហំប៉ុនគ្នា គឺស្មើនឹងប្រវែងបាតគុណនឹងពាក់កណ្ដាលកំពស់ ។

$$\text{ផ្ទៃ} = \frac{\text{ប} \times \text{ព}}{២} \quad \text{ឬ} \quad \text{ប} \times \frac{\text{ព}}{២}$$

## អាទិត្យ ទី ៣.– ការរកបាតនឹងកំពស់នៃត្រីកោណ




វិធាន – ១- ដើម្បីនឹងរកប្រវែងបាតនៃត្រីកោណ គេត្រូវយកផ្ទៃនៃត្រីកោណ ចែកនឹងពាក់កណ្ដាលកំពស់ ឬយកផ្ទៃគុណនឹងពីររួចចែកនឹងកំពស់ ៖

$$\text{ប} = \text{ផ្ទៃ} : \frac{\text{ព}}{២} \quad \text{ឬ} \quad \frac{\text{ផ្ទៃ} \times ២}{\text{ព}}$$

២– ដើម្បីនឹងរកប្រវែងកំពស់ នៃត្រីកោណ គេត្រូវយកផ្ទៃនៃត្រីកោណ បែកនឹងពាក់កណ្ដាលបាត ឬយកផ្ទៃគុណនឹងពីររួចបែកនឹងបាត ៖

$$ក = ផ្ទៃ : \frac{ប}{២} \quad ឬ \quad \frac{ផ្ទៃ \times ២}{ប}$$

អាទិត្យទី៤.– រៀនសាដើមដោយឲ្យសិស្សធ្វើចំណោទជំពូកនេះឲ្យបានច្រើនថែម ដើម្បីឲ្យបានចាំវិធានស្ទាត់ ៗ

---

# បរិច្ឆណាដ្ឋាន

## ឆ្នាំ ១

មេរៀនទី១.– សាបញ្ជាក់អំពីមេលេខគុណ

របៀបបង្រៀន

១.– ចោទសួរសិស្សឲ្យបានចាំមេលេខគុណឲ្យច្បាស់ ដូចជារបៀបហាត់គិតដោយប្រាជ្ញា ដូចជា = ៦ បីដងត្រូវជាប៉ុន្មាន ? ៤ ប្រាំពីរ

ផងត្រូវជាប៉ុន្មាន? ឲ្យសិស្សឆ្លើយបានភ្លាម ៗ ថាត្រូវជា ១៨ ។ ២៨ ។ ហោចសួរបែបនេះឲ្យបានច្រើន ឲ្យសិស្សចាំមេលេខគុណឲ្យស្ទាត់តាំងពីមេ ២ ដល់មេ ៩ ។

២.– ការហាត់នៅលើក្ដារខៀន.–

៣' + ៤ = .... ។ ៦' + ៥ = .... ។ ៤' + ៧ = .... ។

៩' + ៣ = .... ។ ៨' + ៦ = .... ។ ២' + ៨ = .... ។

៧' + ៤ = .... ។ ៤' + ៦ = .... ។ ៩' + ៥ = .... ។

៣.– ការហាត់សរសេរនៅក្នុងសៀវភៅ.–

ក.– ៥' + ៦ = .... ។ ៧' + ៤ = ... ។ ៩' + ៧ = ... ។

៦' + ៨ = .... ។ ៩' + ៥ = .... ។ ៧' + ៦ = .... ។

១.– បំណោទ– ខ្ញុំទិញសៀវភៅសរសេរ ៧ ថ្ងៃ ៣ រៀលក្នុងសៀវភៅមួយ ហើយទឹកខ្មៅដៃ ៥ ថ្ងៃ ២ រៀលក្នុងខ្មៅដៃមួយ ៗ តើខ្ញុំចាយអស់ប្រាក់តាំងអស់ប៉ុន្មានរៀល ? ។

មេរៀនទី ២.– រៀនគុណចំនួនដុំនឹងមេគុណ ១ តួ ។

## របៀបបង្រៀន.—

១– សំពត់១មថ្ងៃ ២៤រៀល បើគេទិញសំពត់នោះ៧ម តើត្រូវជាថ្លៃប៉ុន្មាន ? ពន្យល់សិស្សឲ្យឃើញថាត្រូវយក ២៤៛ × ៧. ។ ធ្វើលេខគុណនេះនៅលើក្ដារខៀនបញ្ឈរឲ្យសិស្សមើល ហើយពន្យល់របៀបធ្វើលេខគុណ ។

២– ការហាត់បញ្ឆាក់នៅលើក្ដារខៀន.—

៧៣៛ × ៥ = ។ ៥៧៛ × ៤ = ។

១៤៧៛ × ៣ = ។ ១០៦៛ × ៧ = ។

៣– ការហាត់បញ្ឆាក់នៅលើក្ដារឆ្នួន.—

៥៦៛ × ៤ = ។ ៧៥៛ × ៦ = ។

១២៥៛ × ៣ = ។ ១៣៩៛ × ២ = ។

៤– ការហាត់សរសេរនៅក្នុងសៀវភៅ.—

ក– ចូរធ្វើលេខគុណខាងក្រោមនេះ ៖

៦៨៛ × ៧ = ។ ៥៩៛ × ៥ = ។ ១២៧៛ × ៣ =

១- បំណោទ .- ឪពុកខ្ញុំមានប្រាក់ ៩៧៣ រៀល គាត់ទិញសំពត់ ៣ ម ថ្លៃ ៣៧ រ ក្នុង ១ ម ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ? ។

មេរៀនទី ៣ .- រៀនចែកចំនួននឹងលេខ ១ តួ ។

មេរៀនទី ៤ .- រៀនគុណចំនួនបែងភាគនឹងមេគុណមានលេខ ១ តួ ។

មេរៀនទី ៥ .- រៀនចែកចំនួនបែងភាគ នឹងលេខ ១ តួ ។

មេរៀនទី ៦ .- សាបស្រៀនពីដើមឡើងវិញ ។

## រង្វាស់រង្វាល់

មេរៀនទី ១ .- អំពីលុយ ១ សេន - ៥ សេន នឹងកាក់ ១០ សេន - ២០ សេន ៥០ សេន ។

របស់សំរាប់បង្រៀន .- លុយ ១ ស .- ៥ ស .- កាក់ ១០ ស .- ២០ ស .- ៥០ ស . ។

## របៀបបង្រៀន

១– នាំសិស្សពិនិត្យលុយនឹងកាក់គ្រប់បែបនោះម្ដងមួយ (រូបរាង-រូប-អក្សរ-លេខ) ហើយសួរសាកបញ្ជាក់ ៗ

២– ការហាត់ដូរ – ហាត់ថែម ៗ ឲ្យសិស្សរៀនប្ដូរដូចជាយកប្រាក់កាក់ ៥០ស បួនទៅដូរយកប្រាក់កាក់ ២០ស ត្រូវបានប៉ុន្មាន ? ៗ រៀនថែមលុយដូចជាទិញនំអស់ ២៥ ស- ឲ្យប្រាក់កាក់ ២០ស ពីរទៅ គេត្រូវថែមប៉ុន្មានមកវិញ ? ៗ សូមធ្វើការហាត់បែបនេះឲ្យបានច្រើនបន្តិច ៗ

៣– ការហាត់សរសេរ.– បំណោទ.– ខ្ញុំមានលុយ ៥ស· នោះ៤, មានប្រាក់កាក់ ២០ស- នោះ៣, ហើយនឹងប្រាក់កាក់ ៥០ស- នោះពីរ តើខ្ញុំត្រូវមានប៉ុន្មានសេន ? បើខ្ញុំចាយអស់ ៤៧ ស-ទៅ តើខ្ញុំត្រូវនៅសល់លុយប៉ុន្មានសេនទៀត ? ៗ

**មេរៀនទី ២.– អំពីក្រដាសប្រាក់ ១រ. – ៥រ នឹង ១០រ**

**មេរៀនទី ៣.– អំពីក្រដាសប្រាក់ ២០រ.– ៥០រ.– នឹង១០០រ**

**មេរៀនទី ៤.– សាបង្រៀនឡើងវិញ ៗ**

## ខ្ទួ ១

# ក្មេរផ្ទាន

ចំនួនពី ៨០ ដល់ ១០០ រាប់មួយដប់ ៗ ពី ១ ដល់ ៨០ លេខ

បូកនឹងលេខសង់ការគ្រាទុក វែងចំនួនរបស់ជា ៤ ភាគស្មើគ្នា ។

### បំណោច

មតិសំខា .— ត្រូវឲ្យស៊ីសរាប់ពី ១ ដល់ ៨០— គឺបន្ថែម

មួយ ២ – មួយ ៣ – មួយ ៤ – រួចបន្ថយមួយ ២ – មួយ ៣ – មួយ ៤

ពី ៨០មក ១វិញ ។

មេរៀន.— រាប់មួយ ២០ ។ ពី ១ ដល់ ៨០ ។ រៀនចំនួន៨០

ដល់ ១០០ ។

របៀបបង្រៀន.— បង្រៀនរាប់— មើលចំនួន— សរសេរចំនួន ។

ការរៀបចំជាមុន .— ត្រូវមានរបស់ដូចជាចង្កឹះដល់ចំនួន ១០០

សរសេរលេខពី ១ ដល់ ៨០ នៅលើក្តារខៀន ។

រាប់ម្តងដប់ៗពី ១ ដល់ ៨០.– ឲ្យកូនសិស្សរាប់បង្កើះ១បាច់ៗ ឬមួយសេន ១ បង្គោមៗ ។ ឲ្យរាប់ថា: ១០ – ២០ – ៣០ – ៤០ – ៥០ – ៦០ – ៧០ – ៨០ – ។ ឲ្យរាប់ចុះមកវិញ = ៨០ – ៧០ ៦០ – ៥០ – ៤០ – ៣០ – ២០ – ១០ ។

រាប់ម្តងមួយ ៗ.– ប្រាប់សិស្សថាយើងមាន ៨០ ហើយ ។

ឥឡូវនេះយើងស្រាយបាច់ទី ៩ និងទី ១០ ទៀត ហើយយើងបន្ថែម ១ ម្តងៗ ទៅលើចំនួន ៨០ យើងថា: ៨០ នឹង ១ ត្រូវជា ៨១, ៨០ នឹង ២ ត្រូវជា ៨២; ៨០ នឹង ៣ ត្រូវជា ៨៣. . . . .រហូតដល់ ៩៩ នឹង ១ ត្រូវជាមួយរយ ។

ផ្ទុំលេខនីមួយៗ បានហើយ សូមសរសេរលេខនោះរៀងៗគ្នាតពី ៨០ ទីងដីសពណ៌ ) ។

យើងសរសេរលេខ | ១ | ០ | ០ | យ៉ាងដូច្នេះ ។

សូមពន្យល់ខ្ទង់រយ–ខ្ទង់ដប់ និងខ្ទង់រាយ ។

សូមឲ្យសិស្សសរសេរលេខ ១០០ គ្រប់គ្នានៅលើក្តារខៀន រួចឲ្យរាប់បន្ថែម ម្តង ១ ម្តង ២ ម្តង ៣ ម្តង ៤ ពី ១ ដល់ ១០០ បន្ថយដូចគ្នា ពី ១០០ មក ១ វិញ ។

បង្រៀនមើលចំនួន .– ឲ្យសិស្សមើលចំនួនពី ៩០ ដល់ ១០០ ឲ្យជាឲ្យច្បាស់ៗ ។

បង្រៀនសរសេរចំនួន .– សូមឲ្យសិស្សសរសេរចំនួនតាមគ្រូថា ។

ការហាត់មាត់ទទេ .– ១) មានលេខប៉ុន្មាននៅខ្ទង់ដប់ មានលេខប៉ុន្មាននៅខ្ទង់រាយ ក្នុងចំនួន ប៉ែតសិបប្រាំ– កៅសិបប្រាំបី – ប៉ែតសិបពីរ – កៅសិប.....ល..... ។

២)-ឲ្យរកហើយសរសេរចំនួនបួន–ប្រាំ ដែលមានលេខនៅខ្ទង់ដប់ច្រើនជាងខ្ទង់រាយ ។

ប្រាំ ប្រាំមួយដែលមានលេខរាយច្រើនជាងខ្ទង់ដប់ ។

បំណោទធ្វើ.– ក្នុងទូមួយមានសៀវភៅ ៩៨ លោកគ្រូចែកឲ្យសិស្សម្នាក់ ៣៥ – ម្នាក់ទៀត ៤៦ តើសៀវភៅនៅសល់ប៉ុន្មានទៀត ?

## លេខបូកនឹងលេខសងមានត្រាទុក

សូមបង្រៀនលេខបូក – សងឲ្យមានត្រាទុកក្នុងចំនួនពី ៩១ ដល់

១០០ ឲ្យច្រើនដោយចោទសួរ ហើយដោយធ្វើនៅក្ដារខៀនបណ្ដើរ ៗ

ឧបមាដូចជា ៨០ រៀល នឹង ២ រៀលត្រូវជាប៉ុន្មានរៀល ?

៩០ រៀលដក ៤ រៀល រួចដក ៣ រៀលទៀត តើនៅសល់ប៉ុន្មាន ?

វិធីហាត់សរសេរ .— ចូរធ្វើលេខខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| + ៦៤ រ | + ៥២ ស | − ៩០ ន | − ១០០ ម |
| ២៦ | ៣៩ | ៣៦ | ២៣ |
| រ | ស | ន | ម |

## ចែកចំនួនរបស់ជា ៤ ភាគស្មើគ្នា

ឧបមាដូចជា : ៣២ ; ៤ .

១ )- អ្នកដាំដំណាំម្នាក់ចង់ដាំដើមសាឡាត់ ៣២ ដើមជា ៤ ជួរ តើអ្នកនោះត្រូវដាំសាឡាត់ប៉ុន្មានដើមក្នុង ១ ជួរ ?

តើ ៤ ប៉ុន្មានដង ទើបត្រូវជា ៣២ ? ក្នុងមេរៀនខ្ញុំដឹងថា ៤ ប្រាំបីដងត្រូវជា ៣២ ដូច្នោះ អ្នកដាំដំណាំនោះត្រូវដាំសាឡាត់ ៨ ដើមក្នុង ១ ជួរ ។

២ )- ទាហាន ៣២ នាក់ឈរជាជួរ ក្នុង ១ ជួរមាន ៤ នាក់ តើទាំងអស់មានប៉ុន្មានជួរ ?

ក្នុង ៣២ មាន ៤ ប៉ុន្មានដង ? ខ្ញុំដឹងថា: ៤ ប្រាំបីដងត្រូវជា ៣២ ដូច្នោះខ្ញុំឃើញថា មានទាហានឈរ ៨ ជួរ ។

ឧទាហរណ៍មួយ ៗ ខាងលើនេះ ខ្ញុំចែក ៣២ នឹង ៤ ។ ខ្ញុំថា: ៣២ ចែកនឹង ៤ ត្រូវជា ៨ ។ ខ្ញុំសរសេរ ៣២ : ៤ = ៨ ។

៨ ជាផលហារនៃលេខ ៣២ ចែកនឹង ៤ ។

ការហាត់មាត់ទទេ.— ផ្លែឪឡឹក ១ ថ្លៃ ៤ រៀល តើខ្ញុំទិញបានឪឡឹកប៉ុន្មាន បើខ្ញុំមានប្រាក់ ២០ រៀល? ៣៦ រៀល? ១៦ រៀល? ២៤ រៀល? ២៨ រៀល? ។

បំណោទ.— ១- បងប្អូន ៤ នាក់ចែកមត៌កគ្នា ក្របី ១៦, គោ ២៨ នឹងជ្រូក ៣២, បងប្អូនម្នាក់បានក្របី.... គោ...., នឹងជ្រូក..... ។

២ – ក្ទងទីបញ្ចឹមសត្វមួយ មានមាន់ ៦ ហើយនឹងទន្សាយច្រើន ៗ ជើងសត្វទាំងអស់នេះរួមគ្នាទៅឃើញ ៦០ ។ តើជើងទន្សាយមានប៉ុន្មាន? មានទន្សាយប៉ុន្មាន? ។

## រង្វាស់រង្វាល់

ប្រាក់រៀល – ប្រាក់កាក់ – លុយសេន – បង្ហាត់ក្មេងឲ្យចេះដូរ – នឹងថែមថយលុយ ។

ការរៀបចំជាមុន ៈ– សូមឲ្យរកប្រាក់រៀល – ប្រាក់កាក់ ១០ សេន – ២០ សេន – ៥០ សេន – លុយសេន ១ សេន ។

ការពិនិត្យប្រាក់និងលុយ ៈ– សូមឲ្យសិស្ស ៖

ក )– ពិនិត្យមើលជាតិប្រាក់ – ស្ពាន់ – ទង់ដែង ។

ខ) ពិនិត្យមើលទំហំ – កំពស់ – ពណ៌ – និងអក្សរនៅលើប្រាក់រៀល កាក់ លុយនីមួយ ៗ ។

ការហាត់សំគាល់ស្តាប់សូរសម្លេងប្រាក់ និងលុយ ៈ–

យកប្រាក់និងលុយមកទម្លាក់នៅលើតុ ឲ្យសិស្សប្រុងស្តាប់ហើយឲ្យដឹងថា នេះសូរប្រាក់រៀល – ប្រាក់ ៥ សេន ប្រាក់ ២០ សេន – ១០ សេននិងលុយ ១ សេន ។

រួចឲ្យសិស្សធ្មេចភ្នែកចាំថាឈ្មោះប្រាក់ដែលគ្រូទម្លាក់នៅលើតុ ។

( សូមប្រាប់សិស្សថា ឥឡូវនេះគេពុំសូវចាយប្រាក់រៀលទេ ពីព្រោះប្រាក់រៀលធ្ងន់យកទៅណាពិបាក ហើយយកមិនបានច្រើនផង ដូច្នេះបានជាគេធ្វើក្រដាសប្រាក់ចាយវិញ ឲ្យងាយយកជាប់នឹងខ្លួនទៅណាបានងាយ ៗ ត្រូវឲ្យសិស្សដឹងថា ប្រាក់ក្រដាសដែលយើងចាយ

សព្វថ្ងៃនេះ មានអំណាចចាយបាន តែនៅប្រទេសឥណ្ឌូចិន គឺក្នុងនគរខ្មែរ - នគរលាវនិងនគរយៀកណាម, ។

ការបាត់មាត់ទទេ.- ឲ្យសិស្សគិត - ប្រាក់កាក់ ១០ សេន ៣

ប្រាក់កាក់ ២០ សេន ១

លុយសេន ៦

ទាំងអស់ត្រូវជា . . . . សេន ។

ខ្ញុំមានប្រាក់កាក់ ៥០ សេន ២ ។ ទៅទិញទឹកកកអស់ ១០ សេន ទិញអន្សមចេក ២០ សេន ។ តើខ្ញុំនៅសល់ប៉ុន្មានសេនទៀត ? ។

បំណោទ .- ១)- អ្នកមានលុយ ៥០ សេន, ម្តាយអ្នកឲ្យ ៥០សេនទៀត ឪពុកអ្នកឲ្យ ២៥សេនទៀត ។ រួចអ្នកទិញខ្មៅដៃ ១ថ្លៃ ៩០ សេន ។ តើអ្នកនៅសល់ប៉ុន្មានមកផ្ទះវិញ ? ។

២)- ខ្ញុំទិញសៀវភៅសរសេរ ១ ថ្លៃ ២រុ៤៥ ទិញក្រដាសផ្តិត ១ សន្លឹកថ្លៃ ០រុ៥០ ។ ខ្ញុំនៅសល់ ១រុ៨០ ទៀត ។ តើខ្ញុំមានប្រាក់ប៉ុន្មានទៅផ្សារ ? ។

# មធ្យមដ្ឋាន ទី ២

## វិទ្យាសាស្ត្រ

## អំពីរុក្ខជាតិ

មេរៀនក្នុងខែ ១ .— អំពីចំណែកនៃដើមឈើ: ឫសឈើ ដើមឈើ ស្លឹកឈើ – ផ្កា ផ្លែ និងគ្រាប់ឈើ ។ . រុក្ខវប្បកម្ម ។ (Arboriculture). មេរៀនដូចមានកយៈឈ្មោះខាងលើនេះសឹងមានក្នុងសៀវភៅវត្តស្វាធ្យាយន៍ថ្នាក់អាទិកដ្ឋានតាំងពីទំព័រទី ៣៧ រហូតដល់ទំព័រទី ៤៦ ។

## មេរៀនជាគំរូ

អំពីរុក្ខជាតិ – ឫសឈើ :

ប្រដាប់សំរាប់បង្រៀន .— មុននឹងបង្រៀនមេរៀននេះ សុំយកគ្រាប់សណ្ដែកបាយ សំឡី កែវទឹក – យកសំឡីជ្រលក់ទឹកឲ្យជើម ដាក់ទៅក្នុងកែវ រួចដាក់គ្រាប់សណ្ដែកបាយពីលើ ទុកឲ្យវាដុះ ។

ដល់ពេលបង្រៀន យកកែវបណ្ដុះសណ្ដែកនោះ មកនាំសិស្សពិនិត្យមើលព្រមទាំងមើមការុត មើមដំឡូង គុម្ពស្ពៅ គុម្ពស្រូវ ។ល។

ការនាំសិស្សពិនិត្យមើល .— យកសណ្ដែកបាយដែលបានបណ្ដុះទុកក្នុងកែវពីថ្ងៃមុន មកនាំសិស្សមើល ឃើញឫសសខ្ចីដុះចេញពីគ្រាប់សណ្ដែកនោះ ចាក់ទៅក្នុងសំឡីយ៉ាងត្រង់ ពីលើទៅក្រោម ។ រុក្ខជាតិដែលអ្នកបានឃើញនេះ កើតមកពីគ្រាប់ទាំងអស់ ឯគ្រាប់នោះគ្រាន់តែត្រូវខ្យល់ ចំហាយថ្ងៃនិងទឹក ក៏ចាប់ឫសពន្លកដុះឡើង ។ នាំសិស្សពិនិត្យមើលមើមការុតទៀត ហើយពិចារណាមើមនេះ រូបរាងពណ៌, ក្នុងរូបកាត់មើមការុតនេះជាពីរកំណាត់ ឲ្យសិស្សពិនិត្យមើលសំបកសាច់វាសើមពីព្រោះវាមានទឹកច្រើន ។.

## មេរៀន ·

រុក្ខជាតិ .— រុក្ខជាតិក៏ដូចជាសត្វដែរ វាដុះចម្រើនធំឡើងហើយងាប់ ប៉ុន្តែវាផ្លាស់ប្ដូរទីកន្លែងពុំបានដូចជាសត្វទាំងពួងឡើយ ។

រុក្ខជាតិនីមួយ ៗ គេសំគាល់ឃើញ មានបួនចំណែក គឺៈ ឫស, ដើម ស្លឹក, ផ្កា ។.

ទ្រង់ទ្រាយឫស .— ឫសនីមួយ ៗ មានគម្រប គ្របនៅខាងចុង

ឫសនោះដូចជាម្ជូក ឫសការ៉ុតយើងអាចមើលគម្របនេះឃើញដោយងាយណាស់ ៗ នៅខាងលើគម្របនេះគេឃើញមានរោមឆ្មារ គឺរោមនេះហើយដែលផ្ទុកយកអាហារពីក្នុងដី ចិញ្ចឹមជីវិតនៃរុក្ខជាតិ ៗ ដើមការ៉ុតជា តិណជាតិ រស់នៅក្នុងទឹក ឫសវាគ្មានរោមបែបនេះទេ ៗ គេពិនិត្យឃើញមានរោមនេះនៅឫសសណ្តែក ឫសធំនេះលុះយូរបន្តិចទៅទៀត មានឫសតូច ៗ ដុះចេញសងខាងជាច្រើន ហៅថាឫសរយាង ឫសទាំងនេះក៏មានគម្របនៅខាងចុង ហើយនឹងរោមសំរាប់ផ្ទុកយកអាហារដូចជាឫសកែវដែរ ៗ

សណ្ឋាននៃឫស .— ចូរអ្នកមើលគំរូស្មៅនេះ តើឫសវាមានសណ្ឋានយ៉ាងណា ? (ដុះជាកញ្ចុំ មានទំហំនឹងប្រវែងសឹងតែស្មើគ្នាទាំងអស់ ពាក់ដូចជាឫសទាំងនេះដុះចេញពីគល់មកដំណាលគ្នា ) ៗ ឫសការ៉ុតដូចគ្នានឹងឫសស្មៅនេះដែរឬទេ ? (មិនដូចគ្នាទេ - ការ៉ុតមានឫសកែវធំកម្បោង ហើយវែង ហៅថាមើម ដុះចាក់ជ្រៅទៅក្នុងដី – មើមនេះមានដុះឫសរយាងតូច ៗ ខ្លះទៀត ) ៗ តិណជាតិអ្វីខ្លះ ដែលមានមើមដូចជាការ៉ុត ? ( ថៃថាវ , សាគូ , ដំឡូង , ក្តួច ៗល ៗ ) មើមឈើទាំងនេះយើងយកមកធ្វើជាអាហារមាន[illegible]ណាស់ ៗ មាន

ឫសឬមើមឈើខ្លះទៀតគេយកទៅធ្វើជាថ្នាំ សំរាប់កែរោគផ្សេង ៗ ដូចជាមើមពន្លៃ ញាក្ញុំ ដែលយើងនិយមហៅថា មើមថ្នាំចិនជាដើម ៗ រុក្ខជាតិខ្លះទៀត មានឫសសំយុងដុះចេញពីមែក ដូចជាដើមជ្រៃ ដើមពោធិ៍ ដើមកោងកាង ។ល។ ហៅថាឫសព្រយុង ។

មុខការនៃឫស .— ឫសសំរាប់ក្ដាប់ដើមទៅនឹងដី ហើយរកអាហារប្រយោជន៍នឹងទ្រទ្រង់ជីវិតនៃរុក្ខជាតិ ដោយជញ្ជក់ស្រូបយកទឹកនឹងជីជាតិពីក្នុងដី តាមរោមឆ្មារ ៗ ដែលដុះនៅជុំវិញនៃឫសរយាង ៗ ទឹកនឹងជីជាតិនេះបង្កើតទៅជាជ័រ ។ នេះជ្រាបចូលតាមឫសទៅដើម – មែក រៀងរហូតដល់ស្លឹក ។ ឫសអាចស្រូបយកខ្យល់អាកាសដែលមាននៅក្នុងដី ដើម្បីនឹងបញ្ចេញនូវវត្ថុមិនស្អាត ពីដើមឈើទៅតាមមែក ស្លឹក ។ គឺហេតុនេះហើយដែលអ្នកស្រែចំការត្រូវការភ្ជួររាស់ដីស្រែចំការ មុននឹងដាំដំណាំទាំងឡាយ ប្រយោជន៍ឲ្យដីនោះធូរមានខ្យល់អាកាសច្រើន ។

មេរៀនសង្ខេប .— រុក្ខជាតិមានជីវិតរស់នៅ ដូចជាសត្វដែរ ប៉ុន្តែមិនអាចនឹងផ្លាស់ប្ដូរទីកន្លែងបានឡើយ ហើយគ្មានវិញ្ញាណទៀតផង ។

រុក្ខជាតិមានឫស , ដើម , មែក , ស្លឹក ហើយនឹងផ្កា ។ល។ ឫសធំដែលដុះសំយុងត្រង់ទៅក្រោម ហៅថាឫសកែវ ឬឫសស្នឹង ។ នៅ

ជុំវិញឫសកែវ មានដុះឫសតូចៗជាច្រើន ចាក់ជ្រែងទៅសងខាងហៅថាឫសរយាង នៅឫសនេះមានដុះរោមតូចឆ្មារ ។ ហៅថារោមស្រូបអា-ហារ សំរាប់ជញ្ជក់យកទឹកនឹងដីជាអាហាររុក្ខជាតិ ។ ឯទឹកនឹងដីកឡើងជាជ័រ ហើយជ្រាបឡើងតាមឫសទៅដើម – មែក – ស្លឹក ។

ឫសមានសណ្ឋានមិនដូចគ្នាទេ ឫសខ្លះដុះជាកញ្ចុំ មានប្រវែងនឹងទំហំស្ទើរតែស្មើគ្នាទាំងអស់ ដូចជាស្លៅ, ស្រូវ ។ល។ តិណជាតិខ្លះមានឫសតែមួយ ធំកម្សាន ហើយចុះត្រង់ទៅក្រោមហៅថាមើមដូចជាការ៉ុត, ថៃថាវ ។ល។ ឫសម្យ៉ាងទៀតដុះចេញពីដើម–មែក សំយុងទៅក្រោម ដូចជាដើមជ្រៃ ពោធិ៍ជាដើម ហៅថាឫសព្រយុង ។

ពាក្យសួរក្នុងមេរៀន ។– លក្ខណៈនៃរុក្ខជាតិតើដូចម្ដេច ? រុក្ខជាតិមានប៉ុន្មានចំណែក ? គឺចំណែកអ្វីខ្លះ ? ឫសមានប្រយោជន៍ដល់រុក្ខជាតិយ៉ាងណាខ្លះ ? ឫសមានសណ្ឋានដូចគ្នាទាំងអស់ឬ ? តើឫសនោះមានបែបយ៉ាងណាខ្លះ ? ។ល។

## មេរៀនជាគំរូ ។– អំពីជម្ងឺក្អករបេងរីងរៃ

ជម្ងឺក្អករបេងរីងរៃ ជាជម្ងឺធ្ងន់ម្យ៉ាងឆាប់រហ័សណាស់ បណ្ដាលឲ្យ

ឈឺចាប់គ្រប់ចំណែកនៃគ្រឿងវិញ្ញាណគឺៈ ឆ្អឹង ,សរសៃ, បំពង់រំលាយអាហារ, ស្បែក ។ល។ ប៉ុន្តែជម្ងឺនេះច្រើនកើតនៅសួត ។

ម្យ៉ាងទៀតបណ្ដាលឲ្យរលាកក្រពះ ពោះវៀនធំ-តូច បរិភោគអាហារបំណិរក្រលាយ ចេះតែស្គមហើយក្អកធ្លាក់ឈាមស្រស់ៗ ជួនកាលច្រើនផង ។

ជម្ងឺរបេងនេះ មានច្រើនយ៉ាងណាស់ តែយកតែពីរបែបនេះមកអធិប្បាយ ពីព្រោះមានកើតនៅក្នុងប្រទេសយើងជាអនេក ហើយបណ្ដាលឲ្យស្លាប់មនុស្សក្នុងមួយឆ្នាំៗជាច្រើននាក់ ។

**លក្ខណៈនៃជម្ងឺក្អករបេង** .— ជម្ងឺក្អករបេងបណ្ដាលឡើងដោយហេតុដូចមានតទៅ :

របេងស្ងួតចាប់ផ្ដើមឡើងដោយផ្ដាសាយ រួចក្អកស្ងួតហើយមានស្លេស្ម៍ផង ខ្លួនក្ដៅគ្រុនជាញឹកញយណាស់ ដេកយប់បែកញើសជានិច្ច ឃាត់ឆ្ងាញ់អាហារបន្តិចម្ដងៗ ឯក្អក់ទៀតក៏កាន់តែមានស្លេស្ម៍ច្រើនឡើង ទៅក្នុងកំហាកស្លេស្ម៍នោះមានលាយខ្ទុះនិងឈាមផង អ្នកជម្ងឺស្គមហើយកម្លាំងខ្សោយទៅ ៗ បណ្ដាលឲ្យមរណៈឆាប់ឬយូរតាមកម្លាំងនៃរោគនោះ ។ល។

ហេតុនៃជម្ងឺក្អករបេង.– រោគក្អករបេងកកើតឡើងដោយសត្វមេរោគមានច្រើនណាស់ នៅក្នុងខ្ទុះកំហាក ៗ សត្វមេរោគនេះបណ្ដាលឲ្យស្ងួតស្ងួត ហើយស៊ីពុករបេះដូចជាធូលី ឯសត្វមេរោគនេះនៅរស់ជាដរាបនៅក្នុងកំហាកដែលស្ដោះចេញម្ដង ៗមានសត្វមេរោគនោះជាច្រើនពាន ៗ សត្វមេរោគនេះវាចូលទៅក្នុងសួតយើងតាមផង់ធូលី ដែលខ្យល់បក់ផាត់មកចូលតាមច្រមុះឬ មាត់ដោយដកដង្ហើមចេញ-ចូល លុះចូលទៅដល់ក្នុងខ្លួនយើងគ្រាប់ឈាមសទទួលយកដោយស្រួលពន់ ហើយរុំព័ទ្ធជុំវិញនៃមេរោគនោះ ៗ ទុកជាឈាមសរុំព័ទ្ធយ៉ាងណាក៏ដោយ សត្វមេរោគនេះមិនអាចនៅស្ងៀមទេ វារុករើលុះត្រាតែឈ្នះបានហើយវាបង្កើតកូនចៅជាអនេកប្បមាណ រួចបាចសាចពាសពេញក្នុងសួត វាស៊ីធ្លុះជារន្ធបណ្ដាលឲ្យឈឺផ្ដាសាយជាដំបូង រួចខ្សោយកម្លាំង ស្គមហើយក្អកផង ទោះជាយើងមានកម្លាំងធំធាត់យ៉ាងណាក៏ដោយ ក៏ធន់ទឹងវាពុំបានឡើយ ៗ

ជម្ងឺក្អករបេងម្យ៉ាងទៀត សត្វមេរោគចូលទៅក្នុងក្រពះពោះវៀនធំតូចនៃយើង តាមចំណីអាហារស្រស់ដែលយើងបរិភោគ ដូចជាសាឡាត់, ជីរ ខ្ទឹម ៗ ល ៗ ដែលលាងមិនស្អាតមុននឹងបរិភោគនោះ ឬក៏បរិភោគសាច់ដែលមិនឆ្អិនល្អ ឬផឹកទឹកដោះគោនៃសត្វដែលមានកើតរោគរបេង ៗ

ជម្ងឺក្អករបេងមិនមែនជាជម្ងឺឆ្លងទៅតាមខ្សែឬពូជពីឪពុកឬម្ដាយទៅ

កូន-ចៅនោះទេ ។ កូនដែលកើតពីបិតាមាតាឈឺរបេងរ៉ាំរ៉ៃនោះ គ្មានសត្វមេរោគនេះដោយទៅជាមួយទេ ។ បើកុំឲ្យកូននេះកើតជម្ងឺរបេងធ្ងន់ពីបិតាមាតាត្រូវយកទៅចិញ្ចឹមឲ្យឆ្ងាយពីឪពុកម្ដាយ ឲ្យបរិភោគតែអាហារចំណីល្អជាដរាប ឲ្យដេកនៅដោយទីកន្លែងស្អាត មានខ្យល់អាកាសនឹងពន្លឺព្រះអាទិត្យចេញ-ចូលច្រើនផង កុមារគ្មានកើតជម្ងឺករបេងដូចជាបិតាមាតាវាទេ ។

សេចក្ដីការពារនឹងជម្ងឺករបេង .— ជម្ងឺករបេងមិនជារោគចៀសវាងពុំបាននោះទេ បើយើងធ្វើតាមសេចក្ដីបញ្ញត្តិខាងក្រោយនេះ អាចចៀសវាងជម្ងឺរបេងនេះដោយងាយណាស់ ។

ក — ចូរអ្នកបរិភោគចំណីអាហារឲ្យល្មមហើយឲ្យស្អាតណាស់ផង សាច់ចំអិនឲ្យឆ្អិនល្អ អន្លក់លាងឲ្យស្អាតមែនទែន បោសសំអាតកន្លែងដេកនឹងទីលំនៅឲ្យស្អាតជានិច្ច ហើយបើកទ្វារបង្អួច ឲ្យអស់ប្រយោជន៍ឲ្យខ្យល់អាកាសនឹងចំហាយព្រះអាទិត្យចេញ—ចូលបរិបូណ៌ ចូរធ្វើពលៈវិធីនៅកណ្ដាលធ្លាអាកាសបន្តិចបន្តួចជារាល់ព្រឹក ។

១ — ត្រូវចៀសវាងកុំធ្វើការឲ្យហួសកម្លាំង កុំដើរលេងយប់ឲ្យអត់ងងុយហួសពេលវេលា ត្រូវចៀសវាងអំពើអ្វីដែលនាំឲ្យខ្សោយដល់គ្រឿងប្រដាប់វិញ្ញាណ ។

គ- ត្រូវយកកូនដែលទើបកើតទៅមន្ទីរពេទ្យ សុំឲ្យចាក់ថ្នាំការ-ពាររោគរបេងរ៉ាំរ៉ៃ ។ ដូច្នេះកូនក្មេងនោះអាចចៀសវាងជម្ងឺក្អករបេងរួចអស់មួយជីវិតបាន ។

ឃ- បើកាលណាអ្នកក្អកផ្ដាសាយ ត្រូវរកថ្នាំចាក់ចេញជាប្រញាប់ បើសិនជាក្អករ៉ាំរ៉ៃ ចូរទៅរកគ្រូពេទ្យពិនិត្យរោគនោះភ្លាមកុំទុកឲ្យយូរឡើយ ។

ង- ចូរអ្នកកុំខាកស្ដោះទៅលើដីឬក្ដារកម្រាលឲ្យសោះ បើអ្នកណាមានជម្ងឺក្អករបេង ត្រូវឲ្យខាកស្ដោះទៅកន្ត្រកណាដែលមានដាក់ទឹកលាយក្រេស៊ីលផង រួចយកទៅចាក់ចោលឲ្យឆ្ងាយពីផ្ទះ ហើយលាងនឹងទឹកលាយក្រេស៊ីលឲ្យស្អាតចាំយកមកប្រើទៀត ។

ច- ត្រូវស្ងោរឬដុតចោលវត្ថុណាដែលមនុស្សកើតជម្ងឺក្អករបេងប្រើប្រាស់ ដើម្បីកុំឲ្យឆ្លងទៅមនុស្សដទៃទៀត ។

មេរៀនសង្ខេប.- ជម្ងឺក្អករបេងរ៉ាំរ៉ៃ ជាជម្ងឺធ្ងន់មួយយ៉ាងឆាប់រហ័សណាស់ រាលដាលឲ្យឈឺចាប់គ្រប់ចំណែកខ្លួន គឺសួត, ខួរក្បាល, ឆ្អឹង, បំពង់រំលាយអាហារ, ស្បែក ។ល។

ជម្ងឺរបេងរ៉ាំរ៉ៃបណ្ដាលឲ្យស្លាប់មនុស្សជាអនេក ។ លក្ខណៈនៃ

ពេលនេះ គឺចាប់ដំបូងក្អកមានស្លេស្ម ហើយបណ្ដាលឲ្យខ្សោយស្គមដល់គ្រឿងវិញ្ញាណជាឆាប់ណាស់ ។ សត្វមេរោគដែលបង្កើតជម្ងឺនេះមាននៅពាសពេញក្នុងកំហាកនិងធូលី ។ វាចូលទៅក្នុងគ្រឿងវិញ្ញាណយើង តាមផ្លូវដកដង្ហើមឬតាមចំណីអាហារមិនស្អាតឬមិនឆ្អិនល្អដែលយើងបរិភោគ ។

ជម្ងឺក្អករបេងទាំងឡាយនេះ គេអាចចៀសវាងកុំឲ្យវាកើតបាន ដោយយើងសំអាតខ្លួននិងទីកន្លែងដែលនៅ បើកទ្វារបង្អួចឲ្យធំ ដើម្បីឲ្យខ្យល់អាកាសនិងពន្លឺព្រះអាទិត្យចេញ-ចូលបានដោយងាយ កុំនៅក្នុងបន្ទប់ដែលមានមនុស្សច្រើនហួសចំណុះ កុំបរិភោគអាហារចំណីអាក្រក់ឲ្យសោះ កុំសេពសុរា សុំគ្រូពេទ្យចាក់ថ្នាំការពាររោគនេះ ដល់កុមារាកុមារីដែលទើបនឹងកើត ។ បើសិនណាជាកើតរោគក្អករបេងនេះហើយ ត្រូវប្រញាប់រកគ្រូពេទ្យពិនិត្យមើលទាន់ថ្មី ៗ ទើបកំចាត់រោគនេះបាន ។

ពាក្យសួរក្នុងមេរៀន .- សុំគ្រូតែងពាក្យសួរផងចុះ ។

មេរៀនក្នុងខែ:

១ – អំពីទឹកនឹងអណ្ដូងទឹក ។ ២ – ទឹកផឹកត្រូវដាំឲ្យពុះនៅវេលាដែលមានជម្ងឺ ។

សូមមើលមេរៀនទាំងពីរខាងលើនេះ នៅសៀវភៅវិធីបង្ការរោគ ទំព័រទី ៤៧ និង ៤៨ ។

# ឧត្តមថ្នាក់

## វិទ្យាសាស្ត្រ

មេរៀនជាគំរូ ៖— អំពីខ្យល់អាកាស ។

### ខ្យល់អាកាសមាននៅពាសពេញលើផែនដី ។

ខ្យល់អាកាសដែលនៅជុំវិញខ្លួនយើង គ្មានពណ៌ - ក្លិនទឹងរសជាតិទេយើងមើលពុំឃើញឡើយ ប៉ុន្តែយើងឃើញពពុះខ្យល់ឡើងមកលើផ្ទៃទឹក ។

ព្យាករ ៖— យើងយកដបមួយ ទៅដាក់ផ្កាប់ជិតទឹងក្បាលម៉ាស៊ីនទឹកកំពុងហូរ នោះយើងឃើញទឹកហូរចូលទៅក្នុងដប បានដោយលំបាកណាស់ កំពប់ទៅដីជាងពាក់កណ្ដាល ។ តើពីព្រោះអ្វី ? (ពីព្រោះនៅក្នុងដបនោះមានខ្យល់អាកាសពេញហើយគ្មានរន្ធឲ្យខ្យល់ចេញបាន កាលណាទឹកចូលទៅក្នុងដប ខ្យល់អាកាសប្រានទឹកឲ្យមក

ក្រៅវិញ ) ។ យើងដាក់មាត់ដបឲ្យឃ្លាតឆ្ងាយបន្តិចពីក្បាលម៉ាស៊ីនទឹក ហើយផ្អៀងដបបន្តិច ដើម្បីឲ្យមានផ្លូវខ្យល់ចេញ ទឹកចូលទៅក្នុងដបបានដោយងាយ ។

អវសាន .— ខ្យល់អាកាសមាននៅគ្រប់កន្លែង ទុកជារន្ធតូចឆាបយ៉ាងណាក៏ដោយគង់តែមានខ្យល់នោះដែរ គឺខ្យល់អាកាសដែលព័ទ្ធជុំវិញព្រះធរណី ។ ខ្យល់អាកាសក្ដៅស្រាល ជាងខ្យល់អាកាសត្រជាក់ ខ្យល់អាកាសក្ដៅផាត់ឡើងទៅលើ ទើបខ្យល់អាកាសត្រជាក់បក់មកជំនួសខ្យល់អាកាសក្ដៅវិញ ។ ខ្យល់អាកាសនាំបង្កើតជាខ្យល់បោកបក់ កាលណាអាកាសបោកបក់ខ្លាំងនាំបង្កើតជាខ្យល់ព្យុះសង្ឃរា ។

ប្រយោជន៍នៃខ្យល់អាកាស .— ខ្យល់អាកាសមានប្រយោជន៍ទីងទ្រទ្រង់ជីវិត យើងពុំអាចចៀសវាងបានឡើយ ។ មនុស្ស , សត្វនិងរុក្ខជាតិដកដង្ហើមឥតឈប់ទេ គឺស្រូបយកខ្យល់អាកាសល្អចូលទៅក្នុងខ្លួន ហើយបញ្ចេញខ្យល់អាកាសមិនស្អាតមកក្រៅវិញ ។ បើសិនណាជាយើងយកសត្វអ្វីមួយ ទៅដាក់ក្នុងកែវបំពង់ ហើយគ្របមាត់វាឲ្យជិតកុំឲ្យខ្យល់ចេញចូលបាន មិនយូរប៉ុន្មានទេយើងនឹងឃើញសត្វនោះស្លាប់ ដោយគ្មានខ្យល់អាកាសចេញចូល ។ ដើម្បីឲ្យបានសេចក្ដីសុខសប្បាយ

យើងត្រូវផ្លាស់ប្ដូរខ្យល់អាកាសជារឿយ ៗ នៅក្នុងបន្ទប់ដែលយើងដេកនៅ ។

ខ្យល់បំរុងជាតុ ៖– គេអាចយកថ្មម្យ៉ាងហៅថា អុកស៊ីលិត (Oxilithe) មកធ្វើជាខ្យល់បំរុងជាតុបាន ។ ខ្យល់បំរុងជាតុនេះក៏ដូចជាខ្យល់អាកាសធម្មតាដែរ គឺឥតពណ៌, ឥតក្លិន, ឥតរសជាតិទេ ។ ចំណែកអាហារដែលបរិភោគចូលទៅក្នុងក្រពះ ក៏មានខ្យល់បំរុងជាតុជាយកម្ហូបអាហារនោះដោយសម្រាម ។ ខ្យល់បំរុងជាតុនេះកើតមកពីខ្យល់អាកាសដែលយើងដកដង្ហើម មិនតែប៉ុណ្ណោះខ្យល់បំរុងជាតុជួយគាំពារចំហាយក្ដៅ ឲ្យមាននៅក្នុងខ្លួនយើងជានិច្ច ។

មេរៀនសង្ខេប ៖– ខ្យល់អាកាសជាអរូប ព្រមទាំងគ្មានពណ៌ គ្មានក្លិន, គ្មានរសជាតិផង ខ្យល់នេះមាននៅពាសពេញធរណី ។ ខ្យល់អាកាសរុំព័ទ្ធជុំវិញក្នុងផែនដី ហើយជាគ្រឿងមួយយ៉ាងសំខាន់សំរាប់ទ្រទ្រង់ជីវិតមនុស្ស, សត្វ និងរុក្ខជាតិព្រមទាំងឲ្យភ្លើងឆេះបានផង ។

ខ្យល់អាកាសមានលាយធាតុពីរយ៉ាងគឺ ខ្យល់បំរុងជាតុ ហើយនឹងអាសូត (Azote) ។ ចំហាយខ្យល់បំរុងជាតុបណ្ដាលឲ្យភ្លើងឆេះ ដូចជា

ដែកដុតនេះ មានពន្លឺដោយនៅក្នុងចំហាយខ្យល់បំរុងធាតុ ឯអាសូតសំកប់ឲ្យភ្លើងរលត់ទៅវិញ ។

ពាក្យសួរក្នុងមេរៀន .— សូមគ្រូតែងពាក្យចោទសួរដែរចុះ ។

មេរៀនក្នុង៖

១ -អំពីខ្យល់អាកាស ។ ២- អំពីទឹក ។ ៣ - អំពីទម្ងន់ខ្យល់អាកាសទៅផែនដី ។ល ។

សូមមើលមេរៀនទាំងនេះនៅក្នុងសៀវភៅវិទ្យាសាស្ត្រ ជាភាសាបារាំងថ្នាក់ឧត្តមដ្ឋានពីទំព័រ ២៤០ រហូតដល់ទំព័រ ២៥១ ។.

## វិធីបង្ការរោគ

១ -អំពីអាហារ ។ ២- អំពីភេសជ្ជៈ ។ ៣- អំពីសំអាតសំលៀកបំពាក់ ។ល ។

សូមមើលមេរៀននេះក្នុងសៀវភៅវិទ្យាសាស្ត្រថ្នាក់ឧត្តមដ្ឋានទំព័រ ៧០ - ៧១ - ៧២ - ៧៣ ។ ហើយបង្រៀនតាមរបៀបមធ្យមដ្ឋាន ។

# មជ្ឈិមដ្ឋានទី ១

## វត្ថុស្វាធ្យាយន៍

អាទិត្យទី ១ .– មេរៀនទី ១– ប្រយោជន៍នៃព្រៃឈើ –

គោលសេចក្ដី · –

១ – ខាងចំណីអាហារ ៖ ផ្លែ, ស្លឹក, មើម ....

២ – ខាងគ្រឿងប្រើប្រាស់ ៖ ទូសផុត, គ្រឿងតុបតាំង, ឫស្សី, វល្លិ, ផ្កា, ជ័រ ....

៣ – មានប្រយោជន៍លើអាកាសធាតុ ៖ ជារបាំងទប់ខ្យល់និងទាក់ទឹកភ្លៀងធ្លាក់ឲ្យទៀងទាត់ ។

៤.– សំរួលទឹកជំនន់ ៖ ទឹកភ្លៀងហូរកាត់ព្រៃពុំសូវលឿនគំហុកដោយមានដីនិងឫសឈើស្រូបទប់ ។

មេរៀនទី ២ .– ការអន្តរាយបណ្ដាលពីការធ្វើព្រៃឲ្យវិនាស ។

គោលសេចក្ដី .–

១ – ហេតុដែលនាំឲ្យព្រៃវិនាស ៖

ក – កាប់ឈើខ្ជះខ្ជាយហួសប្រមាណ (មានរំលំដើមយកផ្លែជាដើម)

ខ – ដុតស្រែចំការមិនប្រយ័ត្នឲ្យរាលឆេះព្រៃជិតខាង ។

គ – ការអន្តរាយបណ្តាលពីការធ្វើព្រៃឲ្យវិនាស ។

ក – នាំឲ្យស្រុកក្រខ្សត់ ។

ខ – នាំឲ្យប្រដាប់ប្រើប្រាស់ឡើងថ្លៃ ។

គ – នាំឲ្យភ្លៀងគ្មានកំណត់ ហើយជន់លិចលង់ស្រុកភូមិអស់ដូចនៅប្រទេសតុងកឹង ។

អាទិត្យទី ២ .– មេរៀនទី ១ – ការធ្វើនៅស៊ូ =

សុំគ្រូមើលទស្សនាវដ្តីឆ្នាំនេះ ខែមករាត្រង់ទំព័រសំរាប់អាទិកដ្ឋាន ។

មេរៀនទី ២ .– ការវែរឈ្មោះនិងការដំបាញ – ។

សុំមើលសៀវភៅវត្ថុស្ថាត្យាយន៍សំរាប់អាទិកដ្ឋានទំព័រ ១៤៩ – ១៥០

អាទិត្យទី ៣ .– មេរៀនទី ១ – ឧស្សាហកម្មកើតពីឈើ –

សុំមើលទស្សនាវដ្តីឆ្នាំនេះ ខែមករាត្រង់ទំព័រសំរាប់អាទិកដ្ឋាន ។

មេរៀនទី ២ .– ការធ្វើក្រដាស

សុំមើលទស្សនាវដ្តីឆ្នាំនេះខែមករាត្រង់ទំព័រសំរាប់អាទិកដ្ឋាន ។

## អាទិត្យទី ៤.- រៀនសារដើម ។

### វិធីបង្ការរោគ

### រោគរបេង

គោលសេចក្ដី.- ជារោគឆ្លងអាចចាប់គ្រប់អវយវក្នុងខ្លួន៖ ឆ្អឹង, គ្រឿងប្រដាប់វិញ្ញាណ, គ្រឿងប្រដាប់រំលាយអាហារ, ស្បែក ប៉ុន្តែច្រើនចាប់នៅសួត ។

១-លក្ខណៈ: រោគរបេងស៊ីសួតចាប់ពីផ្ដាសាយធម្មតា រួចបណ្ដាលជាក្អកធ្លាក់ស្លេស្ម ។ ខ្លួនចេះតែក្ដៅរោល អាស្រ័យអ្វីពុំបាន ។ ក្អកកាន់តែមានស្លេស្មខាប់ឡើងហើយញាប់ឡើងៗ មួងៗវែងៗ កំហាកមានឈាមខ្លះទឹងឈាម ។ អ្នកជម្ងឺស្លាប់ដោយរីរៃសោះក្នុងខ្លួន ។

២- ហេតុ- បណ្ដាលពីអតិសុខុមប្រាណកុក" (កុកជាឈ្មោះវេជ្ជបណ្ឌិតដែលរកឃើញមេរោគនេះ)- មាននៅក្នុងកំហាក - កំហាកស្ងួតទៅកើតជាធូលីហុយនាំមេរោគនេះពេញពាសអាចចូលក្នុងសួតយើងបានតាមខ្យល់ដកដង្ហើម ។ រោគរបេងអាចឆ្លងតាមប្រដាប់រំលាយអាហារដែរ

កាលណាយើងអាស្រ័យសាច់ពុំឆ្អិនល្អ ឬយើងអាស្រ័យទឹកដោះគោកើតរបេងពុំបានដាំឲ្យឆ្អិន ។

រោគរបេងមិនមែនជាជម្ងឺឆ្លងស្ពូជទេឡើយ កូនអ្នករបេងកើតឡើងគ្មានជាប់រោគរបេងមកជាមួយឡើយ ។ កាលណាគេយកកូននេះទៅចិញ្ចឹមឆ្ងាយពីមាតាបិតា រស់នៅសុខសាធដូចគេឯង ។

៣– កិច្ចត្រូវការពារខ្លួន–

១– បរិភោគចំណីអាហារស្អាតហើយគ្រប់គ្រាន់ - នៅផ្ទះស្អាតត្រូវហាត់ប្រាណរាល់ថ្ងៃនៅកណ្ដាលខ្យល់អាកាស ។

២– ជៀសវាងកុំឲ្យធ្លាក់កម្លាំង-កុំឲ្យប៉ះត្រជាក់ខ្លាំង ។

៣– ត្រូវចាក់ថ្នាំទារក”.

៤– ត្រូវព្យាបាលរោគផ្ដាសាយកុំបណ្ដោយ ។

៥– ជៀសវាងកុំឲ្យខាកស្ដោះលើដី ។

៦– ធ្វើកិច្ចសម្លាប់មេរោគ ឬដុតចោលរបស់ ទាំងប្រដាប់ប្រដាអ្នកជម្ងឺ ។

# ទាជិកដ្ឋាន

## វត្ថុស្ថាធ្យាយន៍

អាទិត្យទី ១ .— មេរៀនទី ១ ខ្យល់អាកាស ខ្យល់

ប្រដាប់បង្រៀន – ដប, ទឹក, ទៀន, កែវ ។

ការពិសោធន៍ – ច្រមុជដបទៅក្នុងទឹកឲ្យសិស្សឃើញពពុះមកស្ទុះចេញមក ពពុះនេះគឺខ្យល់ដែលនៅក្នុងដប ។

អុជទៀនកណ្ដាលចាលឲ្យឆេះមួយសន្ទុះ រួចយកកែវមកគ្រប ទៀនរលត់គឺមកពីឥតខ្យល់អាកាស ។

សុំចាត់ចែងបង្រៀនតាមមេរៀនក្នុងសៀវភៅវត្ថុស្ថាធ្យាយន៍សំរាប់ថរិច្ចណដ្ឋានទំព័រ ៩៦ – ៩៧ ។

មេរៀនទី ២ .— ព្រះធរណី

ប្រដាប់បង្រៀន – កូនគោល ផ្លែក្រូចពោធិសាត់

មេរៀនសង្ខេប – ដីមានរាងមូលដូចផ្លែក្រូចពោធិសាត់មានមនុស្សនៅពាសពេញទាំងអស់ លើកលែងតែនៅជិតជីវាងជើងនឹង

ខាងត្បូង ។ ព្រះធរណីអណ្តែតនៅក្នុងអាកាសហើយវិលជុំវិញខ្លួនឯងផងនឹង ជុំវិញព្រះអាទិត្យ ។ ចំណែកណាត្រូវព្រះអាទិត្យគឺជាពេលថ្ងៃ ចំណែកណាដែលមិនត្រូវគឺពេលយប់ ។ ព្រះធរណីវិលខ្លួនឯងមួយថ្ងៃមួយយប់បានមួយជុំ ក្នុង ១ យប់មាន ២៤ ម៉ោង ។

អាទិត្យទី ២ .– មេរៀនទី ១ ទឹក

សុំមើលសៀវភៅវិទ្យាសាស្ត្រសំរាប់បរិញ្ញាបត្រដ្ឋានទំព័រទី ៩៧ ៩៨ - ៩៩ ។

មេរៀនទី ២ .– បំហាយទឹក

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ៩៩ នឹង ១០០ ។

អាទិត្យទី ៣ .– មេរៀនទី ១ ពពកទឹកសន្សើម

សុំមើលសៀវភៅដដែលត្រង់ទំព័រ ទី ១០១ នឹង ១០២ ។

មេរៀនទី ២ .– ភ្លៀង

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ១០៣ ។

អាទិត្យទី ៤ .– រៀនសារដើម

សុំគ្រូរកប្រដាប់ទុណ្ហមាត្រ (thermomètre) នឹងប្រដាប់ស្ទង់បរិយា-

គាស (Baromètre) យកមកបង្ហាញ ហើយពន្យល់សិស្សឲ្យចេះមើល របៀបកំណត់គំនូសតាមពេលវេលាផង ។

## វិធីបង្ករោគ

អាទិត្យទី ១. ជម្ងឺអាសន្នរោគ

សុំមើលទស្សនាវដ្ដីឆ្នាំនេះ ខែកុម្ភៈ ត្រង់ទំព័រសម្រាប់មធ្យមដ្ឋាន ទី ១ ហើយស្រង់សេចក្ដីខ្លះបង្រៀនសិស្សតាមការគួរ ។

អាទិត្យទី ២.– ជម្ងឺក្អករបេង

សុំមើលក្នុងទស្សនាវដ្ដីខែនេះត្រង់ទំព័រសម្រាប់មធ្យមដ្ឋាន ទី ១

អាទិត្យទី ៣.– ជម្ងឺអុត

គោលសេចក្ដី.– ជាជម្ងឺធ្ងន់ ហើយជារោគប្រចាំប្រទេសឥណ្ឌូចិន ច្រើនកើតនៅប្រទេសតុងកឹងនៅរដូវត្រជាក់ ។ ច្រើនកើតកូនក្មេងនឹងមនុស្សធំ ។

១ លក្ខណៈ.– ចាប់ឈឺក្បាល, ឈឺខ្នង, ក្អក, ហើយគ្រុនញាក់ ហើយក្ដៅយ៉ាងខ្លាំង រួចចេញកន្ទួលក្រហមពេញខ្លួននឹងមុខ ។

មុខនិងត្របកភ្នែកឡើងហើម ។ បន្ទាប់មកកន្ទួលនោះមានខ្ទុះបែក ហើយក្រៀមរបកចេញទុកស្នាមអស់មួយជីវិត ។

២ – ហេតុ .– អតិសុខុមប្រាណនៅក្នុងខ្ទុះនិងក្រមាឆ្លងដោយការប៉ះពាល់អ្នកជម្ងឺ ឬ ដោយរុយ ។

## ៣ – កិច្ចដែលត្រូវធ្វើនៅពេលកើតជម្ងឺ

១– បញ្ជូនសិស្សឲ្យទៅពេទ្យកាលណាឃើញមានកន្ទួលលើខ្លួនវា

២– ត្រូវបណ្ដុះអុតរាល់លើកព្រោះកិច្ចនេះការពារពុំបានយូរទេ ។

## កិច្ចដែលត្រូវធ្វើចំពោះអ្នកជម្ងឺ .–

១ – ត្រូវដាក់មនុស្សជម្ងឺក្នុងកន្លែងមួយដោយឡែក ឲ្យមនុស្សដែលបានបណ្ដុះអុតហើយបំរើ ដេញរុយកុំឲ្យចូលក្នុងបន្ទប់នោះ ។

២– បង្ខាំងជម្ងឺក្នុងបន្ទប់ទាល់តែជាស្រះស្រឡះ ។ ត្រូវដុតកន្ទេលខ្នើយហើយស្ងោរសំអាតប្រដាប់ដែលអ្នកជម្ងឺបានប្រើ ។

---

# បរិច្ឆេទទីប្រាំ

## វិគ្គស្វាធ្យាយន៍

## អាទិត្យទី ១.– អំពីសត្វ = ឆ្មា

សូមគ្រូឲ្យសិស្សចាប់ឆ្មាតូចមួយយកមកបង្រៀន នាំសិស្សពិនិត្យមើលសត្វឆ្មា ។ ក្បាលឆ្មាដូចម្ដេច ? ឲ្យសិស្សសង្កេតមើលស្បែកឆ្មា ។ ពណ៌ដូចម្ដេច ? មានអ្វីជាចំឡែកពីស្បែកសត្វឯទៀត ? សត្វអ្វីទៀតដែលមានស្បែកដូចឆ្មា ? នៅមាត់មានដុះអ្វី ? ឯពុកមាត់នេះប្រើការដូចម្ដេច ?

សូមឲ្យបើកមាត់វាមើលធ្មេញឆ្មា សណ្ឋានដូចម្ដេច ? ធ្មេញណាធំជាងគេ ? ហេតុដូចម្ដេចបានជាចង្កូមនេះធំជាងធ្មេញឯទៀត ? ព្រោះឆ្មាបរិភោគសាច់ ចង្កូមដុះធំឡើង ដើម្បីទឹងទំពាសាច់ ធ្មេញសត្វណាដែលបរិភោគសាច់ - ក៏ដូច្នេះដែរ ? (ដូចជាឆ្កែ - **ខ្លា** - គេ) ។

ឲ្យសិស្សមើលខ្លួនឆ្មា - រោមឆ្មាសណ្ឋានយ៉ាងណា ? ពាល់ទៅដូចម្ដេច ?

ឲ្យសិស្សសង្កេតមើលជើងឆ្មា - ឆ្មាមានជើងប៉ុន្មាន ? សត្វដែលមានជើងបួនហៅថាសត្វអ្វី ? នៅចុងជើងឃើញមានអ្វី ? ក្រចកឆ្មាយ៉ាងដូចម្ដេច ? (កោងខុបចុះក្រោមស្រួច លិបចូលលូតចេញបានតាមចិត្ត) ។ ឯក្រចកនេះសម្រាប់អ្វី ?

ចាប់ក្រញាំសត្វជាអាហារ ។ ហេតុដូចម្តេចបានជាឆ្មាលាក់ក្រចក កាលណាវាដើរ ? (កុំឲ្យរសឹក) ។ កាលណាវាបញ្ចេញក្រចក ។

ឲ្យឆ្មាដើរ–លោត ដំណើរឆ្មាយ៉ាងដូចម្តេច ? ដើរលបៗ ដំណើរទន់ភ្លន់ ប៉ុន្តែឆាខ្លាំងហើយរហ័សណាស់កាលណាវាចាប់សត្វបរិភោគ ឬមួយតយុទ្ធនឹងសត្រូវ សុំឲ្យគ្រូនិយាយអំពីពុតឆ្មាហើយតែងសេចក្តីសង្ខេបផងចុះ ។

## មេរៀនទី ២ .– អំពីគោ

## អាទិត្យ ទី២.– អំពីមាន់

វត្ថុសំរាប់បង្រៀន - មេមាន់ ពងមាន់ រូបថត .

នាំសិស្សពិនិត្យមើលក្បាលមាន់ ភ្នែកនឹងចំពុះមាន់ ចំពុះរឹងស្រួចសំរាប់ចឹកអាហារ ។ មានអ្វីដុះរុំជុំព័ទ្ធខ្លួន(មានរោមតូចៗ) រោមនេះប្រយោជន៍ដូចម្តេច ? គ្របដណ្តប់ខ្លួនការពារត្រជាក់ ? នៅសងខាងខ្លួនមានអ្វី ? (មានស្លាប ២) ស្លាបនេះមានប្រយោជន៍ដូចម្តេច ? មាន់មានជើងប៉ុន្មាន ? នៅចុងជើងមានអ្វី ?

ឲ្យសិស្សស្ទាបមើលខ្លួនមាន់ ហេតុដូចម្តេចបានជាក្តៅខ្លាំង? (ព្រោះឈាមរត់ញាប់ណាស់)មាន់កើតកូនដូចម្តេច ? ចិញ្ចឹមកូនដូចម្តេច ?

លក្ខណៈសត្វចតុប្បាទនឹងសត្វទ្វិបាទសត្វស្លាប ឲ្យសិស្សប្រៀបសត្វចតុប្បាទនឹងទ្វិបាទខុសគ្នាយ៉ាងណាខ្លះ? ដូចឆ្កែនឹងមាន់ ។ល។

## មេរៀនទី ២.— អំពីត្រី

វត្ថុសំរាប់បង្រៀន - ត្រីមានស្រកា ពងត្រី ទឹកមួយក្អាំ ។ នាំសិស្សពិនិត្យមើលត្រី ។ ខ្លួនត្រីរាងដូចម្ដេច? (វែងធំកណ្ដាល ចុងដើមស្តួចដើម្បីកុំឲ្យរាទឹក ។ លើខ្លួនមានដុះអ្វី? ព្រុយដែលដុះនៅលើខ្នង ឬក្រោមពោះត្រីហៅព្រុយអ្វី? ត្រីមានស្រកីប៉ុន្មាន? នៅត្រង់ណា? នាំសិស្សមើលត្រីហែល ព្រុយទ្រូងហើយនឹងព្រុយពោះប្រយោជន៍ដូចម្ដេច? (កកាយទឹកឲ្យលឿនទៅមុខ) ។ ព្រុយកន្ទុយប្រយោជន៍ដូចម្ដេច? (ប្រើជាចង្កូតប្រយោជន៍បត់ចុះបត់ឡើង) ។ ព្រុយខ្នងហើយនឹងព្រុយឯទៀត (សំរាប់ទប់ទល់ត្រីឲ្យនៅនឹងបានក្នុងទឹក) ។ ហេតុដូចម្ដេចបានជាស្រកីពណ៌ក្រហម? (ព្រោះមានឈាម) ។ ត្រីដកដង្ហើមតាមស្រកីនេះឯង ត្រីទុកនៅលើគោករស់នៅបានឬទេ? យកពងត្រីឲ្យសិស្សមើល ត្រីកើតកូនដូចម្ដេច? ។ ឲ្យសិស្សរាប់ឈ្មោះត្រីណាដែលស្គាល់ ។

**អាទិត្យទី ៣.—** អំពីបង្កួយ -- ក្អែប -

**អាទិត្យទី ៤.—** អំពីមេអំបៅ — ខ្យងនឹងជន្លេន ។

# វិធីបង្ការរោគ

អាទិត្យទី១.– កិច្ចដែលត្រូវប្រព្រឹត្ត វេលាដែលមានជម្ងឺឆ្លង

រំលឹកសិស្សថាក្នុងគ្រានេះមានជម្ងឺឆ្លង ដូចជាជម្ងឺអាសន្នរោគ, (ជម្ងឺនេះឆ្លងរហ័សណាស់) ធ្វើឲ្យអ្នកស្រុកវិនាស ហេតុនេះត្រូវឲ្យប្រយ័ត្នមាំមួន ឲ្យសិស្សរៀបរាប់ អំពីជម្ងឺដែលឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត អ្វីដែលនាំជម្ងឺពីម្នាក់ទៅម្នាក់ទៀត ? ។

កាលណាមានជម្ងឺឆ្លងនៅក្នុងផ្ទះ ត្រូវឲ្យមានសេចក្ដីប្រយ័ត្នដូចមានខាងក្រោមនេះ បំបែកអ្នកជម្ងឺឲ្យនៅដោយខ្លួន អ្នកដែលថែជម្ងឺត្រូវមានសំលៀកបំពាក់មួយប្រដាប់ផ្សេងមួយ សំរាប់ចូលទៅក្នុងបន្ទប់ជម្ងឺត្រូវលាងដៃនឹងទឹកសាប៊ូរួចនឹងស្រា កាលណារួចការហើយ ។

អាទិត្យទី២.– កិច្ចដែលត្រូវប្រព្រឹត្តវេលាដែលមានជម្ងឺឆ្លង

(តមក)

ការរំងាប់នឹងជៀសវាងមេរោគវេលាដែលអ្នកមានជម្ងឺមិនទាន់ជា ត្រូវឲ្យសំអាតទីលំនៅតូចតាំង មិនត្រូវឲ្យមានសំរាមស្អុយរលួយនៅជិតផ្ទះសំបែង កុំប្រើប្រាស់របស់អ្នកជម្ងឺ ដល់អ្នកជម្ងឺជាហើយទីកន្លែងអ្នកជម្ងឺ

ត្រូវសំអាតរំងាប់មេរោគនឹងទឹកក្រេសិល បើកទ្វារបង្អួចឲ្យស្រឡះ ឲ្យពន្លឺនឹងអាកាសចូលឲ្យបានច្រើន ។

សំលៀកបំពាក់អ្នកនោះ ត្រូវយកទៅស្ងោរលាងចេញ ប្រដាប់ប្រដាដែលអ្នកជាប់កាន់ប៉ះពាល់ក៏ត្រូវធ្វើដូចនេះដែរ ។

## អាទិត្យទី ៣ .– កិច្ចដែលត្រូវប្រព្រឹត្តវេលាដែលមានជម្ងឺ (តមក)

ការប្រយ័ត្នខាងចំណីអាហារ សុំឲ្យគ្រូហាមប្រាមសិស្សកុំឲ្យបរិភោគផ្លែឈើខ្ចីដូចជាស្វាយខ្ចីជាដើម បន្លែស្រស់ឬបន្លែផ្លែឈើណាដែលស្អុយរលួយទោះបន្តិចបន្តួចក៏ដោយ ។

នៅផ្ទះសំបែងចំណីអាហារត្រូវគ្របឲ្យជិតកុំឲ្យរុយវារោម អាហារទៀត ត្រូវឲ្យធ្វើថ្មីៗ ហើយចំអិនប្រាកដ គឺទុកឲ្យយូរលើភ្លើងសមបរិភោគ ។

ភេសជ្ជៈ ដូចជាទឹកនេះក៏ដែរ បើប្រើទឹកទន្លេឬទឹកអណ្តូងត្រូវយកមកដាំឲ្យពុះចំនួន ២០ មីនុត ការប្រើទឹកតែក៏ជាកិច្ចមួយយ៉ាងសំខាន់ដែរ ក៏ប៉ុន្តែត្រូវឲ្យទឹកពុះយូរ ហើយមិនត្រូវចាក់ទឹកត្រជាក់លាយវេលារៀបនឹងផឹក ។

ការប្រយ័ត្នជាធំ បើកាលណាដម្លើងកង់ក្តុមកង់ស្រុកហើយ ត្រូវតែចូលទៅឲ្យគ្រូពេទ្យចាក់ថ្នាំ ការពារខ្ទមមុនដកាប ៗ សុំគ្រូតែងសេចក្ដីសន្ធើបផងចុះ ៗ

អាទិត្យ ទី ៤ .-- សាបជ្រៀនជាថ្មីឡើងវិញ ៗ

អាទិត្យទី ១.- អំពីខ្យល់អាកាស

វត្ថុសំរាប់បង្រៀន - ផ្ចិត ១ កូនដបតូច ទឹក ១ កែវ

នាំសិស្សសង្កេត បញ្ជាក់ឲ្យដឹងថាមានខ្យល់នៅគ្រប់ទីតម្បន់ ៗ ឲ្យសិស្សទាំងអស់គ្នាយកសៀវភៅបក់មុខខ្លួនឯង ល្ហើយឬទេ? ៗ ពីព្រោះអ្វី? ដោយមានខ្យល់មកប៉ះនឹងមុខ ៗ ហេតុដូចម្ដេចបានជាស្លឹកមែកឈើកំរើក? មកអំពីមានខ្យល់បក់ផាត់ ៗ យើងមើលខ្យល់ឃើញឬទេ? យើងមើលពុំឃើញទេ ៗ តើមានក្លិនឲ្យយើងសំគាល់បានឬទេ? ខ្យល់ឥតក្លិនទេ ៗ ដូចម្ដេចបានជាយើងដឹងថាមានខ្យល់? ព្រោះយើងសំគាល់ដោយខ្យល់មាននៅកន្លែងណាខ្លះ? មានគ្រប់តម្បន់នៅជុំវិញខ្លួនយើង ៗ សូម្បីតែបន្ទប់តូចមួយ ក៏មានខ្យល់ដែរ ៗ សូមឲ្យគ្រូយកកូនដបទៅជ្រមុជក្នុងទឹក ឲ្យសិស្សពិនិត្យមើលពពុះខ្យល់ដែលធាត់ឡើង ៗ

ខ្យល់មានប្រយោជន៍ដូចម្ដេចខ្លះ? មនុស្ស – សត្វ – ដើមឈើ នៅក្នុងទឹក លើគោករស់បានតែដោយសារខ្យល់ ។ បើសិនណាជាគេយកកូនសត្វអ្វីមួយទៅដាក់ក្នុងកែវហើយគ្របឲ្យជិត កូនសត្វនោះនឹងស្លាប់ដោយគ្មានខ្យល់ដកដង្ហើម មនុស្សយើងដែលស្លាប់នឹងលង់ទឹកនោះក៏សណ្ឋានដូចគ្នាដែរ ។

មេរៀនទី ២ .– អំពីខ្យល់បក់

អាទិត្យទី ២ .– អំពីទឹក – អំពីភ្លៀង

អាទិត្យទី ៣ .– អំពីព្រែក អំពីសមុទ្រ

អាទិត្យទី ៤ .– រៀនសាអំពីដើមឡើងវិញ

សូមគ្រូតែងរបៀបបង្រៀនដូចរបៀបអធិប្បាយខាងលើនេះ ។

## វិធីបង្ការរោគ

មេរៀនទី១.– អំពីការសំអាតនៅទីធ្លាសាលារៀននឹងជាយ ៗ ។

សូមគ្រូប្រាប់សិស្សថានៅទីធ្លាសាលារៀនត្រូវឲ្យស្អាតជានិច្ច មិនត្រូវយកក្រដាសសម្បកកាកអំពៅឬវត្ថុអ្វី ៗ ដែលនាំឲ្យមិនស្អាតទៅបាចសាច

នៅទីនោះទេ ពីព្រោះទីនេះហើយ គឺជាទីលំអមួយដែរ អ្នកទាំងឡាយគេដើរទៅមក គេសំគាល់ឃើញថាបើទីនេះស្អាត កន្លែងឯទៀតក៏ស្អាតដូចគ្នាដែរ ខាងក្រៅក៏ដូចជាខាងក្នុងបន្ទប់រៀនដែរ ។

កន្លែងណា ៗ ក្តី ដែលគេមើលទៅឃើញល្អ គឺដោយមានសួនច្បារ ដោយមានមន្ទីររៀបរយ ឯទីធ្លាសាលាអ្វីបើគ្មានសួនច្បារគ្មានមន្ទីររៀបរយ បើជាស្អាតជានិច្ច ក៏ល្អដូចទីដែលមានសួនច្បារមានផ្ទះត្រឹមត្រូវនោះដែរ

## មេរៀនទី ២.– អំពីការសំអាតបង្គន់

សូមគ្រូប្រាប់សិស្សថា បើនឹងត្រូវការទៅបង្គន់ បត់ជើងធំ ត្រូវឲ្យចំប្រហោង មិនត្រូវទៅខុសពីកន្លែងដែលគេសំរាប់ឲ្យធ្វើនោះទេ ឬជិតបង្គន់ ឬខាង ៗ ជាយ ឯបត់ជើងតូចក៏ដូច្នេះដែរ ត្រូវឲ្យត្រង់កន្លែងដែលគេទុកបំរុងទឹងឲ្យបត់ជើងនោះ ទោះបីបើជាស្រួកាន់យ៉ាងណាក៏ដោយ មិនត្រូវទៅធ្វើតែពាស ដូចគេឃើញតែគ្រប់សាលា ត្រង់កន្លែងដែលដោះទុក្ខសត្វមិនស្អាតសោះ បើកាលណាមិនស្អាតដូច្នេះទេនឹងបណ្តាលឲ្យធុំក្លិនមកដល់ទីកន្លែងដែលរៀនសូត្រ នាំឲ្យធ្វើការមិន

កើត ទៅជាខ្យល់ចាប់ឬវិលមុខ ដោយសេចក្ដីស្ទាកក្រោកនោះ ម្យ៉ាងទៀតនឹងនាំបណ្ដាលឲ្យមានជម្ងឺផង ។

---

# លោកនីតិ

(សម្រាប់គ្រប់ថ្នាក់)

## ៣- សាលាដំបូង

សាលាដំបូងមានតាំងនៅគ្រប់ទីរួមខេត្តទាំងអស់នៃកម្ពុជរដ្ឋ ។ សាលាដំបូងខេត្តកណ្ដាល គឺសាលាលុឃុននៅក្រុងភ្នំពេញ ខាងមុខព្រះបរមរាជវាំង ។

នៅសាលាដំបូងនីមួយៗ មានចៅហ្វាយសាលា មានព្រះរាជអាជ្ញា សុភាចារបុរស ក្រឡាបញ្ជី និងសមុហបញ្ជី ។ សាលាដំបូងសម្រាប់ជំនុំជំរះកាត់សេចក្ដី រឿងអាជ្ញាគតិបានត្រឹមតែបទមជ្ឈិមទេ គឺធ្វើទោសដាក់គុកពី ៦ ថ្ងៃ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់តាមកំណត់ច្បាប់សម្រេចទុកមក ។ បើនៅខេត្តណាគ្មានសាលាលហុនោះ សាលាដំបូងក៏ត្រូវជំនុំជំរះបទលហុដែរ ។

## ៤- សាលាក្រុមហោទ

សាលាក្រុមហោទ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិនិត្យមើលពាក្យហោទផ្សេងៗ ដែលគូក្តីមិនសុខចិត្តនឹងការជំនុំជំរះនៅសាលាដំបូងនានា ។ លុះបានពិចារណាមើលរឿងទាំងនោះឃើញថាត្រឹមត្រូវហើយ ឬមួយនៅចន្លោះកិច្ចម្យ៉ាងៗ ពុំទាន់បានពេញសេចក្តីបរិបូណ៌ ក៏ធ្វើពត៌មានតាមហេតុពិនិត្យនោះជូនទៅសាលាឧទ្ធរណ៍ជំនុំជំរះ ។ សាលាក្រុមហោទនេះជាសាលាជំនួយនៃសាលាឧទ្ធរណ៍ ។

## ៥- សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានតែមួយទេ តាំងនៅក្រុងភ្នំពេញសម្រាប់ពិភាក្សាកាត់សេចក្តីសាជាថ្មីដែលគូក្តីមិនសុខចិត្តនឹងសាលាលហុ សាលាដំបូងដែលជំនុំជំរះកាត់សេចក្តីបើកផ្លូវឧទ្ធរណ៍ អំពីបទលហុក្តីមជ្ឈិមក្តី ។

## ៦- សាលាឧក្រិដ្ឋ

សាលាឧក្រិដ្ឋសម្រាប់ជំនុំជំរះទោសជនដែលចូល ជាបទឧក្រិដ្ឋ តាំងពីទោស ៦ ឆ្នាំ ទៅដល់ទោសអស់ជីវិត ឬត្រូវពិឃាតជីវិតបង់ ។

បើមិនសុខចិត្តនឹងសាលក្រមសាលាឧក្រិដ្ឋទេ ត្រូវប្តឹងទៅសាលាវិនិច្ឆ័យជាសម្រេច ។

## ៣ សាលាវិនិច្ឆ័យ

សាលាវិនិច្ឆ័យក៏មានតែមួយ ដូចជាសាលាឧទ្ធរណ៍និងឧក្រិដ្ឋដែរ តាំងនៅក្រុងភ្នំពេញជាសាលាធំបំផុតសម្រាប់ពិនិត្យរឿងហេតុនឹងជំនុំជំរះសាឡើងវិញ ក្តីណាដែលគូវិវាទប្តឹងសាទុក្ខមិនសុខចិត្តនឹងសាលក្រមសាលាលហុ, សាលាដំបូង, សាលាឧក្រិដ្ឋ, ឬសាលាឧទ្ធរណ៍, បើពិភាក្សាទៅឃើញថាគាត់ខុសនឹងច្បាប់ ក៏ជំនុំជំរះសាជាថ្មីឡើងវិញឲ្យបានត្រឹមត្រូវ បើឃើញថាជំនុំជំរះបានសុចរិតតាមច្បាប់ហើយ នោះត្រូវបដិសេធពាក្យបណ្តឹងសាទុក្ខចោលចេញ ។

សាលាជំនុំជំរះក្តីក្នុងកម្ពុជរដ្ឋ ផុតអស់ត្រឹមសាលាវិនិច្ឆ័យនេះហើយ ។

# មេសូត្រត់មាត់

(សំរាប់គ្រប់ថ្នាក់)

## ១– ត្រូវការពារជម្ងឺឆ្លង.– បណ្ដាលអំពីរុយ

បើចង់ដឹងថា អំពីគ្រឿងការ- ពារនូវអន្តរាយ
រឿងកេតបណ្ដាល ពីរុយទាំងឡាយ អ្នកមើលបានងាយ
ដែលដាក់លើថាស ៗ ដួសមកថ្មីៗ គ្មានលាយឲ្យអ្វី
ចំណីស្អាតណាស់ ប៉ុន្តែមិនគ្រប របស់លើថាស
ក្នុងតែប្រទះ ឃើញហេតុដូចម្ដេច ៗ នៅមុខទ្វារផ្ទះ
សម្រាមចាក់ជះ ទោះបីច្រើនតិច មិនបានគ្របក្ដិត
ពិនិត្យមើលកិច្ច រោគមួយគគ្រិច របេងរីងរៃ ៗ
បម្លងជម្ងឺ រោគក្អកក្អួតឈឺ ដើរស្ដោះពាសដី
ដោយដឹតចំហាយ ស៊ុះសាយចូលផ្ទៃ របេងរីងរៃ
គ្រប់ប្ដីប្រពន្ធ ៗ

ពន្យល់ពាក្យ.– នូវ = នឹង ៗ គគ្រិច = ក្រខ្វក់គួរឲ្យខ្ពើម ៗ

ផ្ទៃ = ពោះ ៗ

## ២- ត្រូវការពារជម្ងឺឆ្លង .- បណ្ដាលអំពីរុយ (ត)

រុយរោមគំរង់ រណ្ដៅអន្ទង់ លាមកបង្គន់
បង្គន់ប្រមោយ ដោយដើរជាប់ផ្ទួន ហើយហើរតយគន់
ចុះជាន់អាហារ ៗ បើគ្មានគម្រប នឹងយកមកគ្រប
ពីគ្រោះបង្ករ បង្កជារោគ បរិភោគអាហារ
អាពាធកាយា ដោយសារសត្វរុយ ៗ ត្រូវអ្នកប្រយ័ត្ន
គិតគូតាមអត្ថ ដេកដើរអង្គុយ ប្រយោជន៍កំចាត់
កំចាយសត្វរុយ បម្ទំសំអុយ ឲ្យកើតរោគា ៗ

ពន្យល់ពាក្យ .- គំរង់= មនុស្សឬសត្វស្លាប់ ស្អុយរលួយ
លាមក = អាចម៍ ៗ អាពាធ = ឈឺ ៗ អត្ថ = សេចក្ដី ៗ

---

## ៣- ជម្ងឺអុត - បណ្ដុះអុត

ជម្ងឺអុតអាច ឆ្លងឆាប់កំណាច ពិសពុលសម្បើម
សម្រាប់មនុស្សជា កាលគ្រាពីដើម រោគានេះឆ្អើម

ស្លាប់ពល់តែឆ្នាំ ៗ ឥឡូវនេះណា ជម្ងឺអុតអា

មិនអាចងឹងទ្រាំ សឹងតែបង់បាត់ ស្ងប់ស្ងាត់ព្រោះថ្នាំ

ពដការថែទាំ ដោះបណ្ដុះអុត ៗ គ្រប់ក្មេងទាំងឡាយ

បង់សុខសប្បាយ ឲ្យកាយបរិសុទ្ធ មានចិត្តបងចាំ

រកថ្នាំមឱសថ ដោះបណ្ដុះអុត ទើបផុតរោគា ៗ

ពន្យល់ពាក្យ.– ពល = កម្លាំង ៗ ដោះ = ឆ្កឹះ = ឬចោះ ៗ

បរិសុទ្ធ = គ្មានលាយឡំ , ស្អាត ៗ ឱសថ = ថ្នាំ ៗ

---

## ៤ – ជម្ងឺអុត – បណ្ដុះអុត (ត)

តាមច្បាប់វិន័យ វិធីពេទ្យស្ដី ពីគ្រឿងការពារ

ត្រូវដោះបណ្ដុះ ឆ្នាំដំបូងគ្រា ដែលកូនកើតជា

ទារកមកនោះ ៗ បណ្ដុះកុំខាន លុះក្មេងនោះបាន

ធំឡើងចំពោះ អាយុ ១០ ឆ្នាំ ចូរចាំត្រូវដោះ

កុំឲ្យជ្រុលហួស ៤ ឆ្នាំដោះម្ដង ៗ កាលណាមានភ័យ

ដម្រីអុតព្រៃ ចូលលុះស្រុកផង ត្រូវដោះបណ្ដុះ
គ្រប់គ្នាតែម្តង កុំឲ្យកន្ទង ចាស់ក្មេងប្រុសស្រី ។
បើមិនបានដោះ មិនបានបណ្ដុះ អុតដូចសំដី
មនុស្សចាស់ច្រើនស្លាប់ រោគរំលប់ថ្មី ហេតុនេះប្រុសស្រី
កុំបីប្រហែស ។

ពន្យល់ពាក្យ ·– វិន័យ = ច្បាប់ ។ ទារក = កូនក្មេងដែលមាន អាយុពី ១ ខែទៅដល់ ១ ឆ្នាំ ។ រំពាស់ = អាសន្ន- រោគគ្រប់យ៉ាង ។

## ៥·– ការរចនា

រចនាទាំងឡាយមានច្រើនពិត នាំកើតគំនិតបែកប្រាជ្ញា
ធៀវឆ្លាតសង្វាតក្នុងកិច្ចការ ចំរើនប្រាជ្ញានឹងស្មារតី ។
បម្លាក់គំនូរនឹងកំណាព្យ កែពាក្យច្រៀងរាំដូរល្បែងទ្រី
ក្បូរក្បាច់រំលេចដម្បាញក្តី គប្បីយល់ថាការរចនា ។

ពន្យល់ពាក្យ.- រចនា= ការតាក់តែង, ការធ្វើឲ្យវិចិត្រផ្សេងៗ ។
ឆ្មៀវឆ្មាត= ប្រសប់, ប៉ិន, ស្ទាត់ ។ ដូរ្យតន្ត្រី=
គ្រឿងភ្លេងដេញដំផ្លុំកូត ។

---

## ៦.- បម្លាក់

បម្លាក់ជាងឆ្លាក់ឆ្មៀសប្រសប់ រូបយក្សគន្ធព្វអប្សរា
ក្រវិលព័ទ្ធព័ន្ធអញ្ជានផ្កា រូបសត្វបក្សាទេវតាគ្រុឌ ។
ដូចជាឆ្លាក់ក្បាច់នៅជញ្ជាំង ឆ្លាក់រូបចម្បាំងតាំងតយុទ្ធ
ដែកជាប់សម្រាប់ទម្លុះមុត ល្អផុតដោយដៃជាងចំណាន ។

ពន្យល់ពាក្យ .– បម្លាក់= រូបឆ្លាក់ក្បាច់ដែលគេឆ្លាក់ ។
គន្ធព្វ= ទេវតាពួករបាំ ។ អប្សរា= ស្រីអប្សរ,
ស្រីសួគ៌ ។ អញ្ជាន= វល្លិមួយយ៉ាងដើមទន់លូត
ស្អិតមូលល្អិតមានផ្កាព័ណ៌ខៀវស្រស់ៗ គ្រុឌ= ឈ្មោះ
បក្សីមានក្នុងរឿងបុរាណថាជាជំនិះនៃព្រះវិស្ណុ
(យកគំរូមកបង្ហាញ) ។ តយុទ្ធ= ច្បាំង ។
ចំណាន= ស្ទាត់, វាងវៃ ។

រោងពុម្ពខ្មែរ